ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***

ឆ្នាំទី ៤ លេខ ៤ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រម

២៤-០១-១៩៩៦- ព្រះរាជក្រម នស/រកម/០១៩៦/០១ ច្បាប់ស្ដីពីការបង្កើតក្រសួង អប់រំ_យុវជន និង កីឡា ១៣១

២៤-០១-១៩៩៦-ព្រះរាជក្រម នស/រកម/០១៩៦/០២ ច្បាប់ស្ដីពីការបង្កើតក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ ១៣៣

២៤-០១-១៩៩៦- ព្រះរាជក្រម នស/រកម/០១៩៦/០៣ ច្បាប់ស្ដីពីការបង្កើតក្រសួង សាធារណការ និង ដឹកជញ្ជូន ១៣៥

២៤-០១-១៩៩៦- ព្រះរាជក្រម នស/រកម/០១៩៦/០៤ ច្បាប់ស្ដីពីការបង្កើតក្រសួង យុត្តិធម៌ ១៣៧

២៤-០១-១៩៩៦- ព្រះរាជក្រម នស/រកម/០១៩៦/០៥ ច្បាប់ស្ដីពីការបង្កើតក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ១៣៨

២៤-០១-១៩៩៦-ព្រះរាជក្រម នស/រកម/០១៩៦/០៦ ច្បាប់ស្ដីពីការបង្កើតក្រសួង សុខាភិបាល ១៤០

២៤-០១-១៩៩៦- ព្រះរាជក្រម នស/រកម/០១៩៦/០៧ ច្បាប់ស្ដីពីការបង្កើតក្រសួង ការពារជាតិ ១៤២

២៤-០១-១៩៩៦- ព្រះរាជក្រម នស/រកម/០១៩៦/០៨ ច្បាប់ស្ដីពីការបង្កើតក្រសួង មហាផ្ទៃ ១៤៤

២៤-០១-១៩៩៦- ព្រះរាជក្រម នស/រកម/០១៩៦/០៩ ច្បាប់ស្ដីពីការបង្កើតទីស្ដី ការគណៈរដ្ឋមន្ត្រី ១៤៦

២៤-០១-១៩៨៦- ព្រះរាជក្រម នស/រកម/០១៩៦/១០ ច្បាប់ស្តីពីការបង្កើតក្រសួង
ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១៤៨
២៤-០១-១៩៨៦- ព្រះរាជក្រម នស/រកម/០១៩៦/១១ ច្បាប់ស្តីពីការបង្កើតក្រសួង
ផែនការ ១៥០
២៤-០១-១៩៨៦- ព្រះរាជក្រម នស/រកម/០១៩៦/១២ ច្បាប់ស្តីពីការបង្កើតក្រសួង
អភិវឌ្ឍន៍ជនបទ ១៥២
២៤-០១-១៩៨៦- ព្រះរាជក្រម នស/រកម/០១៩៦/១៣ ច្បាប់ស្តីពីការបង្កើតក្រសួង
កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១៥៤
២៤-០១-១៩៨៦- ព្រះរាជក្រម នស/រកម/០១៩៦/១៤ ច្បាប់ស្តីពីការបង្កើតក្រសួង
ពត៌មាន ១៥៦
២៤-០១-១៩៨៦- ព្រះរាជក្រម នស/រកម/០១៩៦/១៥ ច្បាប់ស្តីពីការបង្កើតក្រសួង
ទេសចរណ៍ ១៥៨
២៤-០១-១៩៨៦- ព្រះរាជក្រម នស/រកម/០១៩៦/១៦ ច្បាប់ស្តីពីការបង្កើតក្រសួង
ពាណិជ្ជកម្ម ១៦០
២៤-០១-១៩៨៦- ព្រះរាជក្រម នស/រកម/០១៩៦/១៧ ច្បាប់ស្តីពីការបង្កើតក្រសួង
សង្គមកិច្ចការងារ និងអតីតយុទ្ធជន ១៦២
២៤-០១-១៩៨៦- ព្រះរាជក្រម នស/រកម/០១៩៦/១៨ ច្បាប់ស្តីពីការបង្កើតក្រសួង
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១៦៤
២៤-០១-១៩៨៦- ព្រះរាជក្រម នស/រកម/០១៩៦/១៩ ច្បាប់ស្តីពីការបង្កើតក្រសួង
ធម្មការ និង សាសនា ១៦៦
២៤-០១-១៩៨៦- ព្រះរាជក្រម នស/រកម/០១៩៦/២០ ច្បាប់ស្តីពីការបង្កើតក្រសួង
ប្រៃសណីយ៍ និងទូរគមនាគមន៍ ១៦៨
២៤-០១-១៩៨៦- ព្រះរាជក្រម នស/រកម/០១៩៦/២១ ច្បាប់ស្តីពីការបង្កើតក្រសួង
បរិដ្ឋាន ១៧០
២៤-០១-១៩៨៦- ព្រះរាជក្រម នស/រកម/០១៩៦/២២ ច្បាប់ស្តីពីការបង្កើតក្រសួង
កិច្ចការនារី ១៧២

២៤-០១-១៩៩៦- ព្រះរាជក្រម នស/រកម/០១៩៦/២៣ ច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ១៧៤
២៤-០១-១៩៩៦- ព្រះរាជក្រម នស/រកម/០១៩៦/២៤ ច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ១៧៦
២៤-០១-១៩៩៦- ព្រះរាជក្រម នស/រកម/០១៩៦/២៥ ច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ១៧៨
២៥-០១-១៩៩៦- ព្រះរាជក្រម នស/រកម/០១៩៦/២៦ ច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ១៨០
២៦-០១-១៩៩៦- ព្រះរាជក្រម នស/រកម/០១៩៦/២៧ ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃធនាគារជាតិនៃកម្ពុជា ១៩៧
២៦-០១-១៩៩៦- ព្រះរាជក្រម នស/រកម/០១៩៦/២៨ ច្បាប់ស្ដីពីការបង្ក្រាបល្បែងស៊ីសង ២១៩
២៦-០១-១៩៩៦- ព្រះរាជក្រម នស/រកម/០១៩៦/២៩ ច្បាប់ស្ដីពីការផ្ដល់សច្ចាប័ន លើកិច្ចព្រមព្រៀង ស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៤ រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាមានិតចិន ២២៣

I - ខុទ្ទកាល័យព្រះមហាក្សត្រ

១ - ព្រះរាជក្រម

ព្រះរាជក្រម នស/រកម/០១៩៦/០១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជននិងកីឡា ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងអប់រំ យុវជននិងកីឡា

មាត្រា ១ : ត្រូវបានបង្កើតក្រសួងអប់រំ យុវជននិងកីឡា ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា២ : ក្រសួងអប់រំ យុវជននិងកីឡា មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រង លើវិស័យអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣: ក្រសួងអប់រំ យុវជននិងកីឡា ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអម ដោយរដ្ឋ លេខាធិការនិង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

មាត្រា ៤: ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជននិងកីឡាត្រូវកំណត់ ដោយអនុក្រឹត្យ ។

មាត្រា ៥: បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦: ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/០២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុង កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

មាត្រា ១: ត្រូវបានបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២: ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រង លើវិស័យវប្បធម៌ និង វិចិត្រសិល្បៈ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣: ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអម ដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

មាត្រា ៤: ការរៀបចំរចនាសម្ព័ន្ធ និង ការប្រព្រឹត្តិទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវកំណត់ ដោយអនុក្រឹត្យ ។

មាត្រា ៥: បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦: ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/០៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុង កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន

មាត្រា ១: ត្រូវបានបង្កើតក្រសួងសាធារណៈការនិងដឹកជញ្ជូន ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២: ក្រសួងសាធារណការនិងដឹកជញ្ជូន មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រង លើវិស័យសាធារណការ និងដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣: ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយ រដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

មាត្រា ៤: ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវកំណត់ ដោយអនុក្រឹត្យ ។

មាត្រា ៥: បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦: ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/០៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុង កម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌ ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងយុត្តិធម៌

មាត្រា ១ : ត្រូវបានបង្កើតក្រសួងយុត្តិធម៌ ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងយុត្តិធម៌ មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រង លើវិស័យយុត្តិធម៌ នៃព្រះរាជាណាចក្រ កម្ពុជា ។

មាត្រា ៣ : ក្រសួងយុត្តិធម៌ ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការ និង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងយុត្តិធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/០៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុង កម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលរដ្ឋសភាបានអនុម័ត នាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

មាត្រា ១ : ត្រូវបានបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រង លើវិស័យឧស្សាហកម្ម សិប្បកម្ម រ៉ែ និងថាមពល នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអម ដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/០៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុង កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្ដីក្រាបបង្គំទូលស្នើសុំអំពីសម្ដេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្ដីពីការបង្កើតក្រសួងសុខាភិបាល ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្ដីទាំងស្រុងដូចតទៅ ÷

ច្បាប់

ស្ដីពី

ការបង្កើតក្រសួងសុខាភិបាល

មាត្រា ១ : ត្រូវបានបង្កើតក្រសួងសុខាភិបាល ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងសុខាភិបាល មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រង លើវិស័យសុខាភិបាល នៃព្រះរាជា ណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងសុខាភិបាល ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយ រដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល ត្រូវកំណត់ដោយ អនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្ថលេខា

នរោត្តម សីហនុ

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

ព្រះរាជក្រម នស/រកម/០១៩៦/០៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុង កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងការពារជាតិ

មាត្រា ១ : ត្រូវបានបង្កើតក្រសួងការពារជាតិ ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងការពារជាតិ មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រង លើវិស័យការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងការពារជាតិ ត្រូវបានដឹកនាំដោយសហរដ្ឋមន្ត្រីឬរដ្ឋមន្ត្រី ដែលអាចអមដោយរដ្ឋលេខាធិការ និង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងការពារជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្ថលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/០៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុង កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រ កាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងមហាផ្ទៃ

មាត្រា ១ : ត្រូវបានបង្កើតក្រសួងមហាផ្ទៃ ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងមហាផ្ទៃ មានសមត្ថកិច្ចដឹកនាំគ្រប់គ្រងរដ្ឋបាលដែនដីគ្រប់ថ្នាក់ លើវិស័យរដ្ឋបាលដឹកនាំគ្រប់គ្រងនគរបាលជាតិ ការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការពារសុវត្ថិភាពជូន ប្រជាពលរដ្ឋ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងមហាផ្ទៃ ត្រូវដឹកនាំដោយសហរដ្ឋមន្ត្រី ឬរដ្ឋមន្ត្រី ដែលអាចអមដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងមហាផ្ទៃ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/០៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុង កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី ដែលរដ្ឋសភាបានអនុម័ត នាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

មាត្រា ១ : ត្រូវបានបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : សមត្ថកិច្ចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី គឺគ្រប់គ្រងចាត់ចែងការងាររបស់ខ្លួនផ្ទាល់ និងសម្របសម្រួលការងារប្រចាំថ្ងៃរបស់គណៈរដ្ឋមន្ត្រី ក្រោមការទទួលខុសត្រូវរបស់នាយករដ្ឋមន្ត្រី ។

មាត្រា ៣ : ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបានគ្រប់គ្រងដោយសហរដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រី ដែលអាចអមដោយ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ព្រមទាំងមានអគ្គលេខាធិការរាជរដ្ឋាភិបាលផង ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

ព្រះរាជក្រម នស/រកម/០១៩៦/១០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដែលរដ្ឋសភាបានអនុម័តនាសម័យ ប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ÷

ច្បាប់

ស្តីពី

ការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

មាត្រា ១ : ត្រូវបានបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ **ព្រះហស្តលេខា**

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ **នរោត្តម សីហនុ**

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

ព្រះរាជក្រម នស/រកម/០១៩៦/១១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ ដែលរដ្ឋសភាបានអនុម័ត នាសម័យ ប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងផែនការ

មាត្រា ១ : ត្រូវបានបង្កើតក្រសួងផែនការ ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងផែនការមានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងលើវិស័យផែនការស្តីពីការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើការអនុវត្តន៍ស្ថិតិ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងផែនការត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងផែនការ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/១២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ

មាត្រា ១ : ត្រូវបានបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងអភិវឌ្ឍន៍ជនបទ មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យអភិវឌ្ឍន៍ជនបទ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ **ព្រះហស្តលេខា**

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ **នរោត្តម សីហនុ**

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

ព្រះរាជក្រម នស/រកម/០១៩៦/១៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រ កាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ ដែលរដ្ឋសភាបានអនុម័ត នាសម័យប្រជុំ លើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ

មាត្រា ១ : ត្រូវបានបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងលើវិស័យ កសិកម្ម នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអម ដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/១៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន ដែលរដ្ឋសភាបានអនុម័ត នាសម័យ ប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងពត៌មាន

មាត្រា ១ : ត្រូវបានបង្កើតក្រសួងពត៌មាន ចំណុះរាជរដ្ឋាភិបាល កម្ពុជា ។

មាត្រា ២ : ក្រសួងពត៌មានមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យពត៌មាននិងសោតទស្សន៍នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងពត៌មាន ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងពត៌មាន ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៨៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ **ព្រះហស្តលេខា**

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ **នរោត្តម សីហនុ**

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

ព្រះរាជក្រម នស/រកម/០១៩៦/១៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រ កាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍ ដែលរដ្ឋសភាបានអនុម័ត នាសម័យ ប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងទេសចរណ៍

មាត្រា ១ : ត្រូវបានបង្កើតក្រសួងទេសចរណ៍ ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងទេសចរណ៍មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រង លើវិស័យទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងទេសចរណ៍ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងទេសចរណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

ព្រះហស្តលេខា

នរោត្តម សីហនុ

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

ព្រះរាជក្រម នស/រកម/០១៩៦/១៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័ត នាសម័យ ប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្ដីពី

ការបង្កើតក្រសួងពាណិជ្ជកម្ម

មាត្រា ១ : ត្រូវបានបង្កើតក្រសួងពាណិជ្ជកម្ម ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងពាណិជ្ជកម្មមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើ វិស័យពាណិជ្ជកម្មក្នុង និងក្រៅប្រទេស នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងពាណិជ្ជកម្ម ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/១៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន ដែលរដ្ឋសភាបានអនុម័តនាសម័យ ប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន

មាត្រា ១ : ត្រូវបានបង្កើតក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យសង្គមកិច្ច វិស័យការងារនិងវិស័យអតីតយុទ្ធជន នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ឬរដ្ឋលេខាធិការមួយរូប ដែលអាចអមដោយអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/១៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រ កាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរដ្ឋសភាបានអនុម័ត នាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្ដីពី

ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

មាត្រា ១ : ត្រូវបានបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើ វិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអម ដោយ រដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធ និង ការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រម នស/រកម/០១៩៦/១៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា ដែលរដ្ឋសភាបានអនុម័ត នាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងធម្មការនិងសាសនា

មាត្រា ១ : ត្រូវបានបង្កើតក្រសួងធម្មការនិងសាសនា ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងធម្មការនិងសាសនា មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រង លើវិស័យធម្មការ និង សាសនា នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងធម្មការនិងសាសនា ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ឬរដ្ឋលេខាធិការមួយរូបដែលអាចអមដោយអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងធម្មការនិងសាសនា ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា
នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/២០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង
កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដែលរដ្ឋសភាបានអនុម័តនាសម័យ ប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

មាត្រា ១ : ត្រូវបានបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើ វិស័យ [illegible]និងទូរគមនាគមន៍ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប [illegible] រដ្ឋលេខាធិ[illegible]មួយរូប ដែលអាចអមដោយអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវកំណត់ដោយ អនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

[illegible] **ហ៊ុន សែន**

[illegible]

ព្រះរាជក្រម នស/រកម/០១៩៦/២១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន ដែលរដ្ឋសភាបានអនុម័ត នាសម័យ ប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់
ស្ដីពី
ការបង្កើតក្រសួងបរិស្ថាន

មាត្រា ១ : ត្រូវបានបង្កើតក្រសួងបរិស្ថាន ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងបរិស្ថានមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងបរិស្ថាន ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/២២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី ដែលរដ្ឋសភាបានអនុម័ត នាសម័យ...
នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ

ច្បាប់

ស្តីពី

ការបង្កើតក្រសួងកិច្ចការនារី

មាត្រា ១ : ត្រូវបានបង្កើតក្រសួងកិច្ចការនារី ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងកិច្ចការនារីមានសមត្ថកិច្ចដឹកនាំ និង គ្រប់គ្រងលើវិស័យកិច្ចការនារី នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងកិច្ចការនារី ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូបជានារី ដែលអាចអមដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងកិច្ចការនារី ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/២៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលរដ្ឋសភាបាន អនុម័តនាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

មាត្រា ១ : ត្រូវបានបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមការគ្រប់គ្រងរបស់នាយករដ្ឋមន្ត្រី ។

មាត្រា ២ : រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានភារកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យអាកាសចរស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលត្រូវបានដឹកនាំដោយអនុរដ្ឋលេខាធិការមួយរូប ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/២៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើក ទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

មាត្រា ១ : ត្រូវបានបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ចំណុះគណៈរដ្ឋមន្ត្រី ។

មាត្រា ២ : រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ មានភារកិច្ចគ្រប់គ្រងមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ក្នុងវិស័យមុខងារសាធារណៈ ។

មាត្រា ៣ : រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវបានដឹកនាំដោយរដ្ឋលេខាធិការមួយរូប ដែលអាចអមដោយអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធ និង ការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/២៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បាន ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ដែលរដ្ឋសភាបាន អនុម័តនាសម័យ ប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ច្បាប់

ស្តីពី

ការបង្កើតរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា

មាត្រា ១ : ត្រូវបានបង្កើតរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា មានសមត្ថកិច្ចសម្របសម្រួល និងធ្វើទំនាក់ ទំនងការងារ រវាងរាជរដ្ឋាភិបាល ជាមួយរដ្ឋសភា ។

មាត្រា ៣ : រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ត្រូវបានដឹកនាំដោយរដ្ឋលេខាធិការមួយរូបដែលអាចអមដោយអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/០១៩៦/២៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

– បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
– បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
– បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់
– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១១ ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមនីដ្ឋាន និង រៀបចំតំបន់អង្គរ ហៅថា « **អប្សរា** »
– បានឃើញព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀបរាមអង្គរ

- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំទឹកដីនគរូបនីយកម្ម និង សំណង់

ប្រកាសអោយប្រើ

ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើក ទី ៥ នីតិកាល ទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់
ស្តីពី
កិច្ចការពារបេតិកភណ្ឌវប្បធម៌

ជំពូកទី ១
បទបញ្ញត្តិទូទៅ

មាត្រា ១ : ច្បាប់នេះមានគោលដៅថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិ និងសម្បត្តិវប្បធម៌ទូទៅ ប្រឆាំងនឹងការបំផ្លិចបំផ្លាញ ការប្រែក្លាយ ការប្តូររូបរាង ការជីករុករក ការផ្ទេរកម្មសិទ្ធិ ការនាំចេញនិង ការនាំចូលដោយខុសច្បាប់ ។

មាត្រា ២ : បេតិកភណ្ឌវប្បធម៌ជាតិគឺជាសម្បត្តិវប្បធម៌ដែលត្រូវបានបង្កើតឡើងឬ ក៏បានឃើញនៅក្នុងទឹកដីនៃមាតុភូមិ ។

មាត្រា ៣ : ច្បាប់នេះអនុវត្តទៅលើសម្បត្តិវប្បធម៌ជាចលនៈ និង អចលនៈ ទោះជាកម្មសិទ្ធិសាធារណៈក្តីឬក៏ជាឯកជនក្តីហើយកិច្ចការពារនេះគឺជាផលប្រយោជន៍សាធារណៈ ។

លើកលែងតែមានបទបញ្ញត្តិផ្ទុយពីច្បាប់នេះ ច្បាប់នេះអនុវត្តទៅលើ សម្បត្តិវប្បធម៌ ដែលជាចំណែកនៃបេតិកភណ្ឌវប្បធម៌ជាតិតែប៉ុណ្ណោះ ។

មាត្រា ៤ : តាមន័យនៃច្បាប់នេះ សម្បត្តិវប្បធម៌គឺរាល់ស្នាដៃរបស់មនុស្សនិង, រាល់ផលិតផលរបស់ធម្មជាតិ ដែលមានចរិតវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈឬសាសនា ដែលឆ្លុះបញ្ចាំងពីដំណាក់កាលនៃ ការវិវត្តន៍របស់អារ្យធម៌ ឬ របស់ធម្មជាតិ ហើយដែលកិច្ចការពារសម្បត្តិវប្បធម៌ទាំងនោះ បំរើផលប្រយោជន៍សាធារណៈ ។

សម្បត្តិវប្បធម៌ ដែលបានរៀបរាប់ក្នុងមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ២

បទបញ្ញត្តិពិសេស

ផ្នែកទី១

ស្ថាប័នគ្រប់គ្រង និង ប្រតិបត្តិ

មាត្រា ៥ : ការលើកគោលនយោបាយទូទៅ ក្នុងវិស័យសម្បត្តិវប្បធម៌ជាតិជាពិសេសដើម្បីការពារថែរក្សា និង លើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ (ក.ជ.វ.ជ) ដែលមានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជាស្ថាប័នប្រតិបត្តិ ។

ដោយឡែកនៅតំបន់សៀមរាបអង្គរ ការការពារថែរក្សា និង លើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិត្រូវប្រគល់អោយអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់ អង្គរហៅថា អាជ្ញាធរអប្សរា ។

ការសម្របសម្រួលភារកិច្ចរវាងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និងស្ថាប័នពាក់ព័ន្ធដទៃ ទៀតត្រូវកំណត់ដោយអនុក្រឹត្យ ។

ផ្នែកទី២

រមណីយដ្ឋានដែលត្រូវការពារ

មាត្រា ៦ : រមណីយដ្ឋានដែលត្រូវការពាររួមមាន :

- ឧទ្យានដែលមានបុរាណវត្ថុ ឬ រមណីយដ្ឋានដទៃទៀតដែលមាន អត្ថប្រយោជន៍សំរាប់បុរាណវិទ្យា នរវិទ្យា ឬ ប្រវត្តិវិទ្យាអាចធ្វើការកំណត់ព្រំដែនបាន ។

– ព្រំដែននៃបរិវេណរមណីយដ្ឋានដែលត្រូវការពារ ត្រូវកំណត់ដោយព្រះរាជក្រឹត្យតាមសំណើរបស់ ក.ជ.វ.ជ ។

ផ្នែកទី៣

បញ្ជីសារពើភណ្ឌ

មាត្រា ៧ : ការចុះបញ្ជីសារពើភណ្ឌ គឺជាការកត់ត្រាបញ្ចូលនូវសម្បត្តិវប្បធម៌សាធារណៈឬឯកជនដែលមានសារៈសំខាន់ខាងផ្នែកវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈឬសាសនា ទោះជាសម្បត្តិទាំងនោះមិនតំរូវអោយចាត់ថ្នាក់ជាប្រញាប់ក៏ដោយ ។

មាត្រា ៨ : ការចុះបញ្ជីសារពើភណ្ឌនេះ ត្រូវប្រកាសឡើងដោយសេចក្ដីសំរេចរបស់អាជ្ញាធរមានសមត្ថកិច្ចដែលមានចែងក្នុងមាត្រា ៥ ។

មាត្រា ៩ : ក្រោយពីបានចុះបញ្ជីសារពើភណ្ឌរួចហើយ ចាំបាច់ត្រូវអោយម្ចាស់កម្មសិទ្ធិឬម្ចាស់កាន់កាប់ទ្រព្យសម្បត្តិនោះ ជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចមួយខែមុននឹងខ្លួនធ្វើសកម្មភាពណាមួយក្នុងបំណងនឹងលក់ ឬ ផ្ទេរកម្មសិទ្ធិ ផ្លាស់ប្តូរទីតាំង បំផ្លាញចោល ប្រែក្លាយផ្លាស់ប្តូររូបរាង ជួសជុល ឬ ធ្វើការស្ដារបនាឡើងវិញនូវសម្បត្តិវប្បធម៌នោះ ។

អាជ្ញាធរមានសមត្ថកិច្ចអាចប្រឆាំង នឹងសកម្មភាពខាងលើបែបនេះបាន លុះត្រាតែ បានចាត់វិធានការសមស្របតាមនីតិក្រមចំណាត់ថ្នាក់ ។

មាត្រា ១០ : ការចុះបញ្ជីសារពើភណ្ឌត្រូវទុកជាមោឃៈបើសិនជាមិនបានបញ្ជូនបន្ថែម នូវ សំណើសុំបញ្ចូលចំណាត់ជាសម្បត្តិវប្បធម៌ក្នុងរយៈពេលប្រាំមួយខែ ចាប់តាំងពីពេលដែល បានជូនដំណឹង ជាលាយលក្ខណ៍អក្សរនោះមក ។

ផ្នែកទី៤

ចំណាត់ថ្នាក់

មាត្រា ១១ : ចំណាត់ថ្នាក់គឺការកត់ត្រាសម្បត្តិវប្បធម៌សាធារណៈ ឬឯកជនទាំងឡាយដែលបានចុះក្នុងបញ្ជីសារពើភណ្ឌ ហើយកិច្ចការពារនោះគឺ ដើម្បីបំរើផលប្រយោជន៍សាធារណៈក្នុងវិស័យវិទ្យាសាស្ត្រប្រវត្តិសាស្ត្រ សិល្បៈ ឬ សាសនា ។

មាត្រា ១២ : សំណើសុំចំណាត់ថ្នាក់ ត្រូវធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចដែលជាអ្នកជូនដំណឹងអោយបានត្រឹមត្រូវជាលាយលក្ខណ៍អក្សរទៅម្ចាស់កម្មសិទ្ធិឬអ្នកកាន់កាប់ ។

មាត្រា ១៣ : បន្ទាប់ពីការជូនដំណឹងជាលាយល័ក្ខណ៍អក្សររួចមក បើសិនជាគ្មានសេចក្តីសំរេចក្នុងរយៈ ពេលដប់ពីរខែ សំណើសុំចំណាត់ថ្នាក់នឹងត្រូវទុកជាមោឃៈ ។

មាត្រា ១៤ : ចំណាត់ថ្នាក់ ត្រូវប្រកាសឡើងដោយសេចក្តីសំរេចរបស់អាជ្ញាធរមានសមត្ថកិច្ច ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើសេចក្តីសំរេចក្នុងរយៈពេលបីខែ គិតចាប់តាំងពីថ្ងៃដែល ម្ចាស់កម្មសិទ្ធិឬម្ចាស់កាន់កាប់បានទទួលលិខិតជូនដំណឹងរបស់អាជ្ញាធរនោះ ។

មាត្រា ១៥ : ចំណាត់ថ្នាក់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់កម្មសិទ្ធិឬម្ចាស់កាន់កាប់ ក្នុងករណីជាចាំបាច់ត្រូវជូនដំណឹងទៅមន្ទីរអភិរក្សអចលនវត្ថុ (មន្ទីរទទួលបន្ទុកគ្រប់គ្រងបញ្ជី អចលនវត្ថុ) ។

មាត្រា ១៦ : ក្នុងករណីដែលម្ចាស់កម្មសិទ្ធិមិនយល់ព្រម ចំណាត់ថ្នាក់សម្បត្តិវប្បធមិនៅតែត្រូវធ្វើជាដដែល ។

មាត្រា ១៧ : ការបង់ខាតដែលបណ្តាលមកពីចំណាត់ថ្នាក់សម្បត្តិវប្បធមិនេះ អាចត្រូវទូទាត់ជាប្រាក់ បំណាច់អោយដល់ម្ចាស់កម្មសិទ្ធិ ។

ពាក្យសុំទារប្រាក់បំណាច់ ត្រូវដាក់មកអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេលបីខែ គិតចាប់ពីថ្ងៃដែលបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ស្តីពីសេចក្តីសំរេច នៃ ចំណាត់ថ្នាក់នេះ ។

ចំនួនប្រាក់បំណាច់ខាងលើនេះ ត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

ការតវ៉ាចំពោះសេចក្តីសំរេចស្តីពីគោលការណ៍ឬពីចំនួនប្រាក់បំណាច់អាចនឹងធ្វើឡើងនៅ ចំពោះមុខតុលាការមានសមត្ថកិច្ច ។

មាត្រា ១៨ : អាជ្ញាធរមានសមត្ថកិច្ចធ្វើតារាង សម្បត្តិវប្បធមិដែលបានចាត់ថ្នាក់រួចហើយជារៀងរាល់ដំណាច់ឆ្នាំ ។

តារាងសម្បត្តិវប្បធមិចាត់ថ្នាក់នេះត្រូវធ្វើតាមខេត្តនីមួយៗ ហើយត្រូវចុះក្នុងរាជកិច្ច ។ ប្រការដែលត្រូវចុះមានជាអាទិ៍ :

–ប្រភេទនៃសម្បត្តិវប្បធមិដែលត្រូវបានចាត់ថ្នាក់

–ទីកន្លែងដែលសម្បត្តិវប្បធមិនោះស្ថិតនៅ

–គោត្តនាមនិងនាមរបស់ម្ចាស់កម្មសិទ្ធិ

–កាលបរិច្ឆេទនៃចំណាត់ថ្នាក់ ។

មាត្រា ១៩ : សម្បត្តិវប្បធម៌ដែលចាត់ថ្នាក់រួចហើយ មិនអាចកែប្រែបានឡើយ ។

មាត្រា ២០ : សម្បត្តិវប្បធម៌ដែលចាត់ថ្នាក់រួចហើយ ដែលជាកម្មសិទ្ធិរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈមិនអាចលក់ឬផ្ទេរកម្មសិទ្ធិបានឡើយ ។

មាត្រា ២១: ជនណាក៏ដោយដែលលក់ឬផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ ដែលបំរុងចាត់ថ្នាក់ឬ ត្រូវបានចាត់ ថ្នាក់រួចហើយ ត្រូវតែ :

–ជូនដំណឹងជាមុនដល់អ្នកទទួល អំពីស្ថានភាពរបស់សម្បត្តិវប្បធម៌ ។

–ជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីចេញប័ណ្ណលក់ឬផ្ទេរ ដោយបញ្ជាក់ពីគោត្តនាម នាមនិងទីលំនៅនៃអ្នកទទួល ព្រមទាំងកាលបរិច្ឆេទនៃការលក់ឬផ្ទេរនោះ ។ បើខ្វះពីបទបញ្ញត្តិខាងលើនេះ ការលក់ឬផ្ទេរនឹងត្រូវចាត់ទុកជាមោឃៈ ។

មាត្រា ២២: ការលក់ឬផ្ទេរកម្មសិទ្ធិនូវសម្ភារៈឬបំណែកផ្សេងៗ ដែលផ្តាច់ចេញដោយខុសច្បាប់ពីសម្បត្តិវប្បធម៌ណាមួយដែលបំរុងចាត់ថ្នាក់ឬបានចាត់ថ្នាក់រួចហើយ ក៏ដូចជារាល់នូវអំពើណាដែលនាំអោយមានការផ្ទេរកម្មសិទ្ធិ ឬកាន់កាប់សម្ភារៈឬផ្នែកណាមួយ នៃសម្បត្តិវប្បធម៌ទៅអោយអ្នកដទៃ ត្រូវទុកជាមោឃៈនិងអសារឥតការ ។

អ្នកដទៃនោះត្រូវរួមទទួលខុសត្រូវជាមួយម្ចាស់កម្មសិទ្ធិក្នុងការរៀបដាក់កន្លែងដើមវិញ នូវសម្ភារៈឬបំណែកដែលខ្លួនបានទទួល ។ ជននោះគ្មានសិទ្ធិនឹងទាមទារជម្ងឺចិត្ត ពីរដ្ឋឡើយ ។

មាត្រា ២៣: សម្បត្តិវប្បធម៌ដែលបំរុងចាត់ថ្នាក់ឬបានចាត់ថ្នាក់រួចហើយពុំអាចត្រូវទទួលការផ្លាស់ប្តូរទីកន្លែង ការបំផ្លិចបំផ្លាញ ការធ្វើអោយខូចខាត ការប្រែរូបរាង ការទទួលការជួសជុលឬស្ថាបនាឡើងវិញ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចដែលជាអ្នកកំណត់លក្ខខ័ណ្ឌនិងត្រួតពិនិត្យការ អនុវត្តការងារនោះឡើយ ។

មាត្រា ២៤ : ម្ចាស់កម្មសិទ្ធិដែលដាក់ពាក្យសុំការអនុញ្ញាតដើម្បីកែប្រែ ជួសជុលសម្បត្តិ វប្បធម៌ណាមួយដែលបំរុងចាត់ថ្នាក់ឬបានចាត់ថ្នាក់រួចហើយ ត្រូវដាក់គំរោងប្លង់ព្រមទាំងឯកសារផ្សេងៗទៀតជូន អាជ្ញាធរមានសមត្ថកិច្ចពិនិត្យនិងសំរេច ។

មាត្រា ២៥ : ម្ចាស់កម្មសិទ្ធិសម្បត្តិវប្បធម៌ត្រូវធានាដល់ការការពារសម្បត្តិវប្បធម៌នោះ ដែលបានចាត់ថ្នាក់រួចហើយ ។

ចំណាយទាំងឡាយលើការជួសជុល ឬថែទាំសម្បត្តិវប្បធម៌នោះ គឺជាបន្ទុករបស់ម្ចាស់កម្មសិទ្ធិ ។ អាជ្ញាធរមានសមត្ថកិច្ចអាចនឹងចេញសងជាភាគខ្លះ ។ ចំពោះចំណាយទាំងស្រុងជា សមត្ថកិច្ចរបស់គណៈរដ្ឋមន្ត្រី ។

មាត្រា ២៦ : អាជ្ញាធរមានសមត្ថកិច្ចជាអ្នកត្រួតពិនិត្យនូវការងារជាបន្ទាន់ក្នុងការជួលជុលសម្បត្តិវប្បធម៌ដែលបានចាត់ថ្នាក់រួចហើយនិងទុកអោយគណៈរដ្ឋមន្ត្រីសំរេច ។

ម្ចាស់កម្មសិទ្ធិសម្បត្តិវប្បធម៌ខាងលើ មិនអាចប្រឆាំងនឹងការអនុវត្តទាំងនោះបានឡើយ ។

មាត្រា ២៧ : អនុភាពនៃការចាត់ថ្នាក់នឹងចាប់មានប្រសិទ្ធភាព ចាប់ពីថ្ងៃដែលបានជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីអំពីសំណើសុំចាត់ថ្នាក់ ។

អនុភាពនោះនៅតែមានតំលៃជានិច្ច ទោះបីសម្បត្តិវប្បធម៌នោះត្រូវប្តូរកម្មសិទ្ធិក៏ដោយ ។

ផ្នែកទី ៥
សិទ្ធិទិញបានមុនគេនិងសិទ្ធិដកហូតកម្មសិទ្ធិ

មាត្រា ២៨: អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិទិញបានមុនគេលើរាល់ការលក់ដូរ សម្បត្តិវប្បធម៌ដែលចុះបញ្ជីសារពើភ័ណ្ឌរួចហើយ កំពុងស្នើចាត់ថ្នាក់ឬបានចាត់ថ្នាក់រួចហើយ ។

ជនណាដែលមានបំណងនឹងលក់សម្បត្តិវប្បធម៌ដែលចែងក្នុងកថាខ័ណ្ឌខាងលើនេះ ត្រូវតែជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ស្តីពីការលក់នេះក្នុងរយៈពេល ៣០ ថ្ងៃជាមុន ។

មាត្រា ២៩: ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់តាំងពីកាលបរិច្ឆេទនៃការទទួលដំណឹងដែលមានចែងនៅ ក្នុងមាត្រា ២៨ កថាខ័ណ្ឌទី ២ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់បញ្ជាក់ជាលាយលក្ខណ៍អក្សរដល់ម្ចាស់កម្មសិទ្ធិ អំពីការសំរេចចិត្តរបស់ខ្លួនដើម្បីទិញយក ឬមិនទិញយកសម្បត្តិវប្បធម៌ដែល ស្នើលក់តាមល័ក្ខខ័ណ្ឌនិងតាមថ្ងៃកំណត់ ។

ការខកខានមិនបានឆ្លើយតបដោយហួសរយៈពេល ៣០ថ្ងៃ ដូចបានចែងក្នុងកថាខ័ណ្ឌ ខាងលើនេះ គឺមានន័យថាជាការបោះបង់មិនអនុវត្តសិទ្ធិទិញបានមុនគេ ។

មាត្រា ៣០: អាជ្ញាធរមានសមត្ថកិច្ចអាចដកហូតកម្មសិទ្ធិអចលនសម្បត្តិវប្បធម៌ ដែលបានចុះក្នុងបញ្ជី សារពើភណ្ឌដែលត្រូវបានបំរុងអោយធ្វើចំណាត់ថ្នាក់ ឬ បានធ្វើចំណាត់ថ្នាក់រួចហើយ អាចត្រូវបានដកហូតកម្មសិទ្ធិតាមបែបបទ ដែលចែងដោយច្បាប់ស្តីពីការដកហូតកម្មសិទ្ធិ ដើម្បីផលប្រយោជន៍សាធារណៈ ។

ជំពូកទី៦

ការធ្វើពាណិជ្ជកម្មលើបុរាណវត្ថុ

មាត្រា ៣១ : ការធ្វើពាណិជ្ជកម្មលើបុរាណវត្ថុផ្សេងៗ អាចអនុញ្ញាតបានក្នុងល័ក្ខខ័ណ្ឌដែល មានចែងក្នុងច្បាប់នេះក្រោយពីមានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច ។ បែបបទនៃការធ្វើពាណិជ្ជកម្ម លើបុរាណវត្ថុត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៣២: លិខិតអនុញ្ញាតនេះត្រូវចុះជាអាទិ៍ : គោត្តនាម នាម លំនៅឋានពាណិជ្ជករ សមត្ថភាព ឯកទេសព្រមទាំងប្រភេទបុរាណវត្ថុ និង មានការបញ្ជាក់ច្បាស់លាស់ពីទីកន្លែងដែលខ្លួនមានបំណង ប្រកបអាជីវកម្មនេះ ។ លិខិតអនុញ្ញាតនេះផ្តល់ជូនសំរាប់រយៈពេល ១ ឆ្នាំ ព្រមទាំងអាចបន្ត ១ ឆ្នាំ ម្តងៗហើយពុំអាចបង្វែរទៅអោយអ្នកដទៃបានឡើយ ។

មាត្រា ៣៣: រាល់ពាណិជ្ជករដែលមានច្បាប់អនុញ្ញាត ត្រូវប្រកាន់ខ្ជាប់នូវកាតព្វកិច្ចដូចតទៅ ÷

ក– បិទសេចក្តីប្រកាសបញ្ជាក់ថា ខ្លួនបានទទួលច្បាប់អនុញ្ញាតអោយធ្វើពាណិជ្ជកម្មបុរាណវត្ថុនៅត្រង់ទ្វារចូលនៃអាគារលក់ដូររបស់ខ្លួន ។

ខ– មិនត្រូវដាក់បុរាណវត្ថុមួយសំរាប់លក់នៅក្រៅអាគារ ដែលខ្លួនបានច្បាប់អនុញ្ញាតអោយប្រកបអាជីវកម្ម ។

គ– ចុះជាប្រចាំក្នុងបញ្ជីកត់ត្រាជាលំអិតនូវបុរាណវត្ថុដែលខ្លួនមាន និង សកម្មភាពលក់ចេញ និង ទិញចូលរាល់ថ្ងៃ ។

ឃ– ត្រូវបង្ហាញដល់ភ្នាក់ងារត្រួតពិនិត្យនូវសៀវភៅបញ្ជីខាងលើនេះ រាល់ពេលណាដែលភ្នាក់ងារទាំងនោះទាមទារពិនិត្យ ។

ង–ត្រូវបិទបញ្ញត្តិត្រង់ប្រការស្តីពីការនាំចេញបុរាណវត្ថុ នៅនឹងអាគារលក់ដូររបស់ខ្លួន ត្រង់កន្លែងដែលងាយមើលឃើញ ។

ច–បង្ហាញបុរាណវត្ថុទាំងអស់ដែលខ្លួនមានចំពោះភ្នាក់ងារត្រួតពិនិត្យតាមសំណូមពរ របស់ភ្នាក់ងារ ។

ឆ–ផ្តល់ទៅភ្នាក់ងារត្រួតពិនិត្យនូវរូបថតបុរាណវត្ថុទាំងឡាយណាក៏ដោយដែលខ្លួនមាន ឬ អនុញ្ញាតអោយភ្នាក់ងារនោះ ថតរូបណាមួយដែលគេចង់បាន ។

ជ–បង្កលក្ខណៈងាយស្រួលដល់ភ្នាក់ងារត្រួតពិនិត្យនៅក្នុងពេលធ្វើអធិការកិច្ច ។

ឈ–ជូនពត៌មានដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងករណីដែលមានការប្តូរទីកន្លែងលក់ដូរ របស់ខ្លួន ។

មាត្រា ៣៤: ភ្នាក់ងារត្រួតពិនិត្យអាចចូលទៅក្នុងអាគារលក់ដូរ ហើយធ្វើការត្រួតពិនិត្យកត់ត្រា សម្បត្តិវប្បធម៌ដែលមាននៅក្នុងអាគារលក់ទាំងនោះនិងផ្ទៀងផ្ទាត់បញ្ជីនៅគ្រប់ ពេល ដែលអធិការដ្ឋានយល់ ឃើញថា ជាការគួរ នឹងធ្វើអធិការកិច្ច ។

ភ្នាក់ងារត្រួតពិនិត្យអាចចូលទៅធ្វើការត្រួតពិនិត្យក្នុងលំនៅឋានរបស់ ពាណិជ្ជករបើសិន ជាលំនៅឋាននោះត្រូវប្រើធ្វើជាឃ្លាំង ឬ អាគារលក់ ស្របទៅតាម ខ្លឹមសារនៃ សេចក្តីអនុញ្ញាតដែលចេញ អោយពាណិជ្ជករនេះ ។

មាត្រា ៣៥: អាជ្ញាធរមានសមត្ថកិច្ចអាចដកហូត លិខិតអនុញ្ញាតធ្វើពាណិជ្ជកម្មលើបុរាណវត្ថុ ពេល ដែលពិនិត្យឃើញម្ចាស់ដែលមានការអនុញ្ញាតនោះធ្វេសប្រហែស ឬ រំលោភ ទៅលើកាតព្វកិច្ចណាមួយ ឬ ដោយសារតែអ្នកនោះបានទទួលការផ្តន្ទាទោសពី តុលាការមានសមត្ថកិច្ចដោយហេតុថា ខ្លួនបានប្រព្រឹត្តល្មើស នឹងបទបញ្ញត្តិនៃ ច្បាប់នេះ ។

មាត្រា ៣៦: នៅពេលដែលលិខិតអនុញ្ញាតត្រូវបានដកហូត ដូចមានក្នុងបទបញ្ញត្តិនៃមាត្រា ៣៥ នោះ ពាណិជ្ជករលែងមានសិទ្ធិទិញបុរាណវត្ថុទៀតហើយ ។

ពាណិជ្ជករនោះនឹងត្រូវអនុញ្ញាតអោយលក់បុរាណវត្ថុដែលខ្លួនកំពុងកាន់កាប់ នៅឡើយក្នុងរយៈពេល មួយមិនលើសពី ៦ ខែ ។

ផ្នែកទី ៧

ការប្រទះឃើញដោយចៃដន្យ

មាត្រា ៣៧ : នៅពេលកំពុងដំណើរការងារផ្សេងៗទៀត ឬសកម្មភាពផ្សេងៗទៀត ហើយបានជួបប្រទះសម្បត្តិវប្បធម៌ដូច ជាប្រាសាទបាក់បែក វត្ថុបុរាណ សំណល់ផ្ទះសម្បែងបុរាណ ទីបញ្ចុះសពបុរាណ សិលាចារឹក ឬសម្បត្តិ វប្បធម៌ដែលទាក់ទងដល់បុរេប្រវត្តិសាស្ត្រ បុរាណវិទ្យាជាតិ ពន្ធុវិទ្យា បាសាណីយភូតវិទ្យាឬក៏សាខាដទៃ ទៀតនៃវិទ្យាសាស្ត្រដែលសិក្សាពីអតីត កាលឬមនុស្សសាស្ត្រ អ្នកដែលបានប្រទះឃើញសម្បត្តិទាំងនេះ និងម្ចាស់អចលនវត្ថុ ត្រូវតែបញ្ឈប់ការងារឬសកម្មភាពនោះ រួចរាយការណ៍ជាបន្ទាន់ជូនភ្នាក់ងារ នគរបាល ក្នុងតំបន់ ។ ភ្នាក់ងារនគរបាលនោះត្រូវបញ្ជូនរបាយការណ៍នេះយ៉ាងប្រញាប់ជូនទៅ អភិបាលខេត្ត–ក្រុង ។ អភិបាលខេត្ត–ក្រុង ត្រូវជូនពត៌មាននេះដល់អាជ្ញាធរមាន សមត្ថកិច្ចដើម្បីចាត់វិធានការចំបាច់ ដើម្បីធានាសង្គ្រោះសម្បត្តិវប្បធម៌និងរមណីយ ដ្ឋានវប្បធម៌នោះ ។

មាត្រា ៣៨: ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលសេចក្ដីរាយការណ៍ដូចមានចែងក្នុងមាត្រា ៣៧ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ជាលាយលក្ខណ៍ អក្សរស្ដីពីការផ្អាកជាបណ្ដោះអាសន្ន នូវការងារជួសជុលឬសាងសង់និងស្ដីពីវិធានការសង្គ្រោះដែលត្រូវអនុវត្ត ។

បើក្នុងរយៈពេល ៣០ថ្ងៃ អាជ្ញាធរមានសមត្ថកិច្ចមិនបានធ្វើកំណត់ជាលាយលក្ខណ៍អក្សរ ជូនជាពត៌មានទៅម្ចាស់អចលនវត្ថុទេនោះ ការផ្អាកជាបណ្ដោះអាសន្នត្រូវទុកជាអសារបង់ ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវសំរេចជាស្ថាពរនូវវិធានការចំពោះការប្រទះឃើញដោយចៃដន្យ ។

មាត្រា ៣៩ : សម្បត្តិវប្បធម៌ជាចលនវត្ថុដែលប្រទះឃើញដោយចៃដន្យ ត្រូវចាត់ទុកជាសម្បត្តិសាធារណៈ ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្ដល់រង្វាន់លើក ទឹកចិត្តដល់អ្នកប្រទះឃើញដោយចៃដន្យដោយកំណត់តាមការស្រុះស្រួលគ្នា ឬ តាមការវាយតម្លៃរបស់អ្នកជំនាញក្នុងរយៈពេល ៣សប្ដាហ៍ក្រោយពីបានរកឃើញ ។

ផ្នែកទី ៨
ការជីករុករកវត្ថុបុរាណ

មាត្រា ៤០: គ្មានជនណាមួយអាចធ្វើការជីករុករកឬធ្វើការវាស់ស្ទង់លើដីឬក្រោមដី ក្នុងគោលបំណងស្រាវជ្រាវរកសម្បត្តិវប្បធម៌ដែលមានផលប្រយោជន៍ដល់ការ សិក្សាខាងបុរេប្រវត្តិវិទ្យា ប្រវត្តិវិទ្យា បុរាណវិទ្យា ជាតិពន្ធុវិទ្យា បាសាណភិភុតវិទ្យាឬសាខានៃវិទ្យាសាស្ត្រផ្សេងៗ ដែលសិក្សាពីអតីតកាល ឬទាក់ទងដល់មនុស្សសាស្ត្រ ដោយមិនបានទទួលច្បាប់អនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ចឡើយ ។

មាត្រា ៤១: មានតែស្ថាប័នវិទ្យាសាស្ត្រដែលមានជំនាញ មានបទពិសោធន៍និងមានធនធានគ្រប់គ្រាន់ហើយដែលត្រូវបានអាជ្ញាធរមានសមត្ថកិច្ចទទួលស្គាល់ទេ ទើបអាចអនុញ្ញាតអោយធ្វើការជីករុករកវត្ថុបុរាណបាន ។

ស្ថាប័នវិទ្យាសាស្ត្របរទេស ដែលបានទទួលច្បាប់អនុញ្ញាតអោយធ្វើការជីករុករកត្រូវតែសហការជាមួយស្ថាប័នវិទ្យាសាស្ត្រជាតិ ក្នុងការអនុវត្តន៍ការងាររបស់ខ្លួន ។

មាត្រា ៤២ : ស្ថាប័នវិទ្យាសាស្ត្រដែលទទួលបានច្បាប់អនុញ្ញាតអោយធ្វើការជីករុករក ត្រូវតែ :

ក_ កត់ត្រាសម្បត្តិវប្បធម៌ដែលរកឃើញនៅក្នុងបញ្ជីពិសេស មួយហើយត្រូវប្រគល់ជូនដល់អាជ្ញាធរមានសមត្ថកិច្ចនៅពេលបញ្ចប់ដំណាក់កាលជីករុករកនីមួយៗ ។

ខ_ ការពារទីលានជីករុករកបុរាណវត្ថុនិងសម្បត្តិវប្បធម៌ដែលរកឃើញ ព្រមទាំងចាត់វិធាន ការចាំបាច់គ្រប់បែបយ៉ាងដើម្បីថែរក្សានិងការពារ ។

គ– ជូនពត៌មានអោយទៀងទាត់ដល់អាជ្ញាធរមានសមត្ថកិច្ច ស្ដីពីការប្រព្រឹត្តិទៅ នៃប្រតិបត្តិការជីករុករកវត្ថុបុរាណ ។

ឃ_ ធ្វើរបាយការណ៍សង្ខេបរួមទាំងសៀវភៅរូបថតសម្បត្តិវប្បធម៌ទាំងអស់ដែលបានរកឃើញនៅពេលបញ្ចប់ដំណាក់កាលជីករុករកនីមួយៗ ។

ង_ ធ្វើរបាយការណ៍វិទ្យាសាស្ត្រមួយលំអិតស្តីពីលទ្ធផលជីករុករកក្នុងកំណត់មួយមិនហួសពីមួយឆ្នាំ គិតចាប់តាំងពីការបញ្ចប់ដំណាក់កាលជីករុករកនីមួយៗ ។

ច_ អនុញ្ញាតអោយភ្នាក់ងារនៃអាជ្ញាធរមានសមត្ថកិច្ចត្រួតពិនិត្យមើលការជីករុករកសម្បត្តិវប្បធម៌រាល់តម្រូវការរបស់អាជ្ញាធរនោះ ព្រមទាំងពិនិត្យបញ្ជីពិសេសដូចមានចែងក្នុងកថាខ័ណ្ឌ " ក " ។

ឆ_អនុញ្ញាតអោយអ្នកស្រាវជ្រាវដទៃទៀតចូលធ្វើការស្រាវជ្រាវ ក្នុងល័ក្ខខ័ណ្ឌដែលពួកអ្នក ស្រាវជ្រាវទាំងនោះសុខចិត្តគោរពសិទ្ធិកម្មសិទ្ធិរបស់ស្ថាប័នវិទ្យាសាស្ត្រនោះ ។

ជ_ជួយអប់រំបណ្តុះបណ្តាលអ្នកបច្ចេកទេស វិទ្យាសាស្ត្រនៅក្នុងស្រុក ។

ឈ_បោះពុម្ពផ្សាយលទ្ធផលវិទ្យាសាស្ត្រស្តីពីការជីករុករកវត្ថុបុរាណដែលធ្វើក្នុងកំឡុងពេល ៥ឆ្នាំ បន្ទាប់ពីការបញ្ចប់នៃការងារ ។

មាត្រា ៤៣ :ស្ថាប័នវិទ្យាសាស្ត្រដែលបានទទួលការអនុញ្ញាតអោយធ្វើការជីករុករកបុរាណវត្ថុមានសិទ្ធិ :

ក_ជាម្ចាស់កម្មសិទ្ធិវិទ្យាសាស្ត្រ ចំពោះវត្ថុដែលបានរកឃើញ ។

ខ_ជាម្ចាស់កម្មសិទ្ធិនៃសម្បត្តិវប្បធម៌ដែលខ្លួនអាចបានទទួលក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៤៤កថាខ័ណ្ឌទី ២ ។

គ_ទទួលអាទិភាពក្នុងការផ្សាយលទ្ធផលវិទ្យាសាស្ត្រនៃការជីករុករកក្នុងល័ក្ខខ័ណ្ឌដែលលទ្ធផលនោះ ត្រូវផ្សាយក្នុងរយៈពេលដូចមានចែងក្នុងមាត្រា ៤២ចំណុច"ឈ" ។

មាត្រា ៤៤: សម្បត្តិវប្បធម៌ទាំងចលនវត្ថុនិងអចលនវត្ថុ ដែលបានរកឃើញដោយស្ថាប័ន វិទ្យាសាស្ត្រ គឺជាសម្បត្តិសាធារណៈ ។

អាជ្ញាធរមានសមត្ថកិច្ចអាចជូនដល់ស្ថាប័នវិទ្យាសាស្ត្រនេះ បាននូវវត្ថុបុរាណមួយដែលដូច គ្នាទាំងស្រុងនឹងវត្ថុដែលមានរួចហើយ ព្រមទាំងវត្ថុណាដែលមិនមែនជាវត្ថុចាំបាច់ដោយហេតុថា មានរក្សាទុករួចហើយនូវវត្ថុដែលមានលក្ខណៈដូចគ្នាបេះបិទនឹងវត្ថុដែលរកឃើញនោះ ទាំងខាងប្រភេទចរនាបទ វត្ថុធាតុ របៀបផលិតក៏ដូចជាមានតម្លៃខាងវិទ្យាសាស្ត្រ ឬសិល្បៈ ។ ការផ្តល់ជូននេះអាចធ្វើបានតែក្នុងល័ក្ខខ័ណ្ឌដែលសម្បត្តិវប្បធម៌នេះត្រូវបានយកមកតម្កល់ទុកក្នុងស្ថាប័នវិទ្យាសាស្ត្របច្ចេកទេសសំរាប់សាធារណជន ។

មាត្រា ៤៥ :អាជ្ញាធរមានសមត្ថកិច្ចធានារ៉ាប់រងត្រួតពិនិត្យការជីករុករកនិងជួយចាត់ វិធានការចាំបាច់ ដើម្បីការពារបរិវេណការដ្ឋាននោះ ។

មាត្រា ៤៦: អាជ្ញាធរមានសមត្ថកិច្ច អាចអនុញ្ញាតអោយធ្វើការជីករុករកនៅលើដីជាកម្មសិទ្ធិឯកជន បន្ទាប់ពីបានជូនដំណឹងជាមុនដល់ម្ចាស់កម្មសិទ្ធិ ។

អ្នកជីករុករកត្រូវធ្វើបញ្ជីសារពើភណ្ឌទីកដីដែលនឹងជីករុករកនោះ ហើយលុះត្រាតែបានទទួលការស្រុះស្រួលពីភាគីទាំងអស់ ទើបអាចចាប់ផ្តើមធ្វើការងាររបស់ខ្លួនបាន ។

អ្នកជីករុករកបុរាណវត្ថុត្រូវធ្វើការងារនោះក្នុងរយៈពេលពីរឆ្នាំ ហើយនឹងអាចបន្តទៀតបាន ក្រោយរយៈពេលពីរឆ្នាំនេះ ។

មាត្រា ៤៧: ម្ចាស់កម្មសិទ្ធិ ក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៤៦ មានសិទ្ធិនឹងកាន់កាប់ដីឡើងវិញនិងទទួលបាននូវប្រាក់បំណាច់ចំពោះការខកខានពុំបានស្នាក់ អាស្រ័យនៅប្រកបមុខរបរនិងចំពោះការបង់ខាតឬខូចខាតផ្សេងៗទៀតជាយថាហេតុ ។

មាត្រា ៤៨: ក្នុងករណីដែលប្រទះឃើញសម្បត្តិវប្បធម៌ជាអចលនវត្ថុ អាជ្ញាធរមានសមត្ថកិច្ចអាចប្រើសិទ្ធិដកហូតស្របតាមច្បាប់ស្តីពីការដកហូតកម្មសិទ្ធិ ដោយយោងទៅលើផលប្រយោជន៍សាធារណៈ ។

មាត្រា ៤៩ : ក្នុងករណីដែលអ្នកមានច្បាប់អនុញ្ញាតអោយធ្វើការជីករុករកបានប្រព្រឹត្តិលើស នឹងកាតព្វកិច្ចណាមួយ ដូចមានចែងក្នុងមាត្រា ៤២ អាជ្ញាធរមានសមត្ថកិច្ចអាចសំរេចដកហូតច្បាប់អនុញ្ញាត ឬ និងសិទ្ធិលើកម្មសិទ្ធិលើកម្មសិទ្ធិវិទ្យាសាស្ត្រនោះមកវិញបាន ។

ការជីករុករកត្រូវផ្អាកសកម្មភាពភ្លាម គិតចាប់ពីថ្ងៃដែលបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ស្តីពីការដកហូតច្បាប់អនុញ្ញាតមកវិញ ។

មាត្រា ៥០: លច្បាប់អនុញ្ញាតអោយធ្វើការជីករុករកត្រូវបានដកហូតមកវិញហើយ អ្នកបានច្បាប់អនុញ្ញាតនោះមិនអាចទាមទារថ្ងៃសងជម្ងឺចិត្តណាមួយ បណ្តាលមកពីការបញ្ឈប់ការរុករក ឬ សោហ៊ុយដែលខ្លួនបានចំណាយនោះឡើយ ។

ផ្នែកទី ៩

ការនាំចេញសម្បត្តិវប្បធម៌

មាត្រា ៥១: ការនាំចេញសម្បត្តិវប្បធម៌ណាមួយទៅក្រៅ ដែនដីកម្ពុជាត្រូវហាមឃាត់បើសិនជាគ្មាន អាជ្ញាប័ណ្ណពិសេសដើម្បីនាំចេញសម្បត្តិវប្បធម៌ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចទេនោះ ។

មាត្រា ៥២: អាជ្ញាធរមានសមត្ថកិច្ចត្រូវចេញសេចក្ដីសំរេចក្នុងរយៈពេលបីខែ គិតចាប់ពីថ្ងៃដែលអ្នកសុំនាំចេញ បានបំពេញទំរង់បែបបទជូនអាជ្ញាធរមានសមត្ថកិច្ចគ្រប់សព្វគ្រប់ហើយ ។

មាត្រា ៥៣: ការនាំចេញសម្បត្តិវប្បធម៌ត្រូវបង់ពន្ធនិងអាករផ្សេងៗ ។

ការកំរិតប្រាក់ពន្ធនិង អាករលើសម្បត្តិវប្បធម៌ត្រូវកំណត់ដោយច្បាប់ ។

មាត្រា ៥៤: មុននឹងផ្ដល់អាជ្ញាប័ណ្ណនាំចេញណាមួយ អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាអោយបានច្បាស់ថា :

ក_ការនាំចេញនឹងមិនបណ្ដាលអោយក្សត់ខ្សោយធនធានបេតិកភណ្ឌវប្បធម៌ជាតិឡើយ ។

ខ_សមុច្ច័យសាធារណៈនៅមានសម្បត្តិវប្បធម៌ដែលមានរូបរាងដូចគ្នាទៅនឹងសម្បត្តិវប្បធម៌ ដែលត្រូវបានស្នើសុំធ្វើការនាំចេញ ។

គ_សម្បត្តិវប្បធម៌ដែលអនុញ្ញាតអោយនាំចេញ មិនមែនជាវត្ថុដែលមានតម្លៃខ្ពស់សំរាប់ផ្នែកពិសេសណាមួយនៃការសិក្សា អំពីវិទ្យាសាស្ត្រអតីតកាលឬវិទ្យាសាស្ត្រមនុស្សទូទៅនោះទេ ។ បែបបទនាំចេញសម្បត្តិវប្បធម៌ ប្រភេទសម្បត្តិវប្បធម៌ដែលត្រូវអនុញ្ញាតអោយនាំចេញ និង ប្រភេទសម្បត្តិវប្បធម៌ដែលមិនអនុញ្ញាតអោយនាំចេញ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥៥: អាជ្ញាធរមានសមត្ថកិច្ចត្រូវចេញអាជ្ញាប័ណ្ណសំរាប់ការនាំចេញសម្បត្តិវប្បធម៌ដូចតទៅ:

- សម្បត្តិវប្បធម៌ដែលបានអោយដល់ស្ថាប័នវិទ្យាសាស្ត្របរទេស ដែលមានការអនុញ្ញាតអោយធ្វើការជីក រុករកស្របតាមមាត្រា ៤៤ កថាខ័ណ្ឌទី ២
- សម្បត្តិវប្បធម៌ដែលបញ្ជូនទៅបរទេសសំរាប់មួយរយៈពេល ដើម្បីតាំងពិព័រណ៍ឬក្នុងទិសដៅសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ
- សម្បត្តិវប្បធម៌ជាថ្នូរជាមួយសម្បត្តិមកពីសារមន្ទីរឬស្ថាប័នបរទេស
- សម្បត្តិវប្បធម៌នាំចូលស្របច្បាប់មកក្នុងទឹកដីកម្ពុជា ប៉ុន្តែក្នុងករណីសម្បត្តិវប្បធម៌ដូចរៀបរាប់ក្នុងកថាខ័ណ្ឌទី ១ ត្រង់ចំណុចទី ២ នៃមាត្រានេះ ការនាំចេញមួយរយៈពេលត្រូវតែគោរពល័ក្ខខ័ណ្ឌផ្សេងៗ ដើម្បីធានាកុំអោយមានការខូចខាតព្រមទាំងការបញ្ជូនមកវិញនូវសម្បត្តិវប្បធម៌ទាំងនោះ ។

មាត្រា ៥៦: ការប៉ុនប៉ងនាំចេញសម្បត្តិវប្បធម៌ដោយគ្មានអាជ្ញាប័ណ្ណ ត្រូវឃាត់ទុកនឹងរឹបអូសសម្បត្តិវប្បធម៌ទាំងនោះ ទុកជាសម្បត្តិសមុច្ច័យសាធារណៈ។

មាត្រា ៥៧ : អាជ្ញាធរមានសមត្ថកិច្ចអាចទាមទារយករាល់សម្បត្តិវប្បធម៌ដែលមានការទំនាស់មិនអោយនាំចេញ ដោយសារមានហេតុផលសំខាន់ៗផ្សេងធ្វើអោយមានការសង្ស័យ ថាប៉ុនប៉ងនាំចេញដោយខុសច្បាប់ ។ សម្បត្តិវប្បធម៌ទាំងនេះត្រូវបញ្ចូលជាសម្បត្តិសមុច្ច័យសាធារណៈ ដោយមានការទូទាត់តំលៃតាមការ ស្រុះស្រួលគ្នាឬតាមការវាយតំលៃរបស់អ្នកជំនាញការ ។

ជំពូកទី ១០

ការនាំចូលសម្បត្តិវប្បធម៌

មាត្រា ៥៨: ការនាំចូលសម្បត្តិវប្បធម៌ដែលបាននាំចេញដោយល្មើសនឹងច្បាប់របស់ប្រទេស ដើមត្រូវហាមឃាត់ ។ បែបបទនាំចូលសម្បត្តិវប្បធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥៩: សម្បត្តិវប្បធម៌ដែលនាំចូលដោយខុសច្បាប់ ត្រូវឃាត់ទុកនិងដាក់ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរមានសមត្ថកិច្ច ។ ឈរលើគោលការណ៍បដិការ រាជរដ្ឋាភិបាលអាចចេញសេចក្តីសំរេចប្រគល់សម្បត្តិវប្បធម៌នោះ ទៅប្រទេសដើមវិញស្របតាមកិច្ចព្រមព្រៀងនិងច្បាប់អន្តរជាតិ ។

មាត្រា ៦០: ចំណាយដែលពាក់ព័ន្ធទៅនឹងការបញ្ជូនសម្បត្តិវប្បធម៌ទៅវិញ គឺជាបន្ទុករបស់រដ្ឋដែលទាមទារ ។

មាត្រា ៦១: សម្បត្តិវប្បធម៌ដែលនាំចូលស្របច្បាប់ ត្រូវតែប្រកាសជូនដំណឹងដល់ភ្នាក់ងារគយ ។ បង្កាន់ដៃដែលទីចាត់ការគយចេញអោយម្ចាស់កម្មសិទ្ធិជាភស្តុតាងនោះ ត្រូវយកមកបង្ហាញភ្នាក់ងារគយឡើងវិញ នៅពេលត្រូវនាំរបស់នោះចេញសាជាថ្មី ។

ជំពូកទី ១១

ទោសប្បញ្ញត្តិ

មាត្រា ៦២: សេចក្តីសំរេចរបស់អាជ្ញាធរមានសមត្ថកិច្ចដោយយកច្បាប់នេះជាមូលដ្ឋាន អាចបើកលទ្ធភាពអោយតវ៉ាបានចំពោះមុខតុលាការ ។

មាត្រា ៦៣: ក_ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ៥ ឆ្នាំ ព្រមទាំងពិន័យជាទឹកប្រាក់តាមតម្លៃដែលអ្នកជំនាញបានប៉ាន់ស្មាន ចំពោះជនណាដែលបានប្រព្រឹត្តល្មើសដោយធ្វេសប្រហែសក្នុងប្រការដូច រៀបរាប់ខាងក្រោមនេះ :

- លក់ ឬផ្ទេរកម្មសិទ្ធិ ប្តូរទីតាំង បំផ្លាញចោល ពង្រិចពង្រិល បំផ្លែងរូបរាងឬជួសជុលស្ថាបនាឡើងវិញនូវសម្បត្តិវប្បធម៌ដែលបានចុះក្នុងបញ្ជីសារពើភណ្ឌ ដោយមិនបានជូនដំណឹងជាមុន (មាត្រា ២៩ កថា ខ័ណ្ឌទី ១) ។
- លក់ ឬផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ដែលបានស្នើអោយចាត់ថ្នាក់ឬដែលបានចាត់ថ្នាក់រួចហើយ (មាត្រា ២១ និង ២៨ កថាខ័ណ្ឌទី ២) ។
- ប្តូរទីតាំង បំផ្លាញចោល ពង្រិចពង្រិល បំផ្លែងរូបរាងឬជួសជុលដោយគ្មានការអនុញ្ញាតនូវសម្បត្តិវប្បធម៌ដែលបាន ស្នើអោយចាត់ថ្នាក់ឬដែលបានចាត់ថ្នាក់រួចហើយ(មាត្រា ២៣ កថាខ័ណ្ឌទី ១) ។
- មិនបានរក្សាការពារដោយត្រឹមត្រូវនូវសម្បត្តិវប្បធម៌ដែលបានចាត់ថ្នាក់រួចហើយដែលខ្លួនជាម្ចាស់ កម្មសិទ្ធិ (មាត្រា ២៥ កថាខ័ណ្ឌទី ១) ។
- ធ្វើ ឬ ប៉ុនប៉ងធ្វើដោយគ្មានច្បាប់អនុញ្ញាតនូវការងារទាំងឡាយណាដែលច្បាប់តំរូវអោយមានការអនុញ្ញាត (មាត្រា ៣១ និង ៤០) ។
- មិនបានបំពេញកាតព្វកិច្ចដែលត្រូវខ្លួនអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ៣៣ និង ៤២ ។
- មិនបានប្រកាសអំពីការរកឃើញសម្បត្តិវប្បធម៌ នៅក្នុងអំឡុងពេលសាងសង់និងមិនបានបញ្ឈប់ការងារនោះភ្លាម(មាត្រា ៣៧) ។
- នាំចេញ ឬប៉ុនប៉ងនាំចេញសម្បត្តិវប្បធម៌ដោយគ្មានការអនុញ្ញាត (មាត្រា ៥១ និង ៥៦) ។
- មិនអនុវត្តតាមល័ក្ខខ័ណ្ឌកំណត់នៃការនាំចេញមួយរយៈ (មាត្រា ៥៥ កថាខ័ណ្ឌទី ២) ។
- នាំចូលសម្បត្តិវប្បធម៌ដោយខុសច្បាប់ (មាត្រា ៥៨) ។
- មិនបានប្រកាសជូនដំណឹងដល់ភ្នាក់ងារគយ អំពីការនាំចូលដោយស្របច្បាប់នូវសម្បត្តិវប្បធម៌ (មាត្រា ៦១ កថាខ័ណ្ឌទី ១) ។

ខ_ជនណាដែលប្រព្រឹត្តបទល្មើសដោយចេតនាដូចចំណុចរៀបរាប់ខាងលើ ត្រូវទទួលទោសជាប់ពន្ធនាគារពី ២ ឆ្នាំ ដល់ ៨ ឆ្នាំ និងពិន័យទ្វេគុណនៃតម្លៃសម្បត្តិវប្បធម៌នោះ តាមតម្លៃដែលអ្នកជំនាញបានប៉ាន់ស្មាន ។

ក្នុងករណីខ្លះដូចមានចែងក្នុងចំណុច (ក និង ខ) ខាងលើនេះ ទោសនេះគ្រាន់តែជាប់ពន្ធនាគារ ឬ គ្រាន់តែបង់ប្រាក់ពិន័យ ។

មាត្រា ៦៤: ទុកបំរុងនៅដដែលនូវបទល្មើសពីទោសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ៦៣ ពិរុទ្ធបាល ដែលបញ្ញត្តិក្នុងមាត្រា ២១, ២២, ៣៥, ៤៩, ៥៦, និង ៥៩ ត្រូវតំកល់ទុកដដែល ។

មាត្រា ៦៥ : បទល្មើសទាំងឡាយត្រូវចុះក្នុងកំណត់ហេតុដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ និង ដោយអាជ្ញាធរមានសមត្ថកិច្ច ជាពិសេសភ្នាក់ងារគយដែលបានធ្វើសម្បថព្រមទាំងដោយមន្ត្រីអភិរក្ស និង បុគ្គលិកដទៃទៀតនៃសារមន្ទីរសាធារណៈដែលត្រូវបានចាត់តាំងនិងបានធ្វើសម្បថចំពោះការងារនេះ ។

ជំពូកទី ៣

អវសានប្បញ្ញត្តិ

មាត្រា ៦៦ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦៧ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខា ព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
នរោត្តម រណឫទ្ធិ ហ៊ុន សែន

បានបង្គំទូលថ្វាយ និងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការ
វប្បធម៌ និងវិចិត្រសិល្បៈរៀបចំទីកដី
នគរូនីយកម្ម និង កំណាង
វណ្ណ មូលីវណ្ណ

ព្រះរាជក្រម នស/រកម/០១៩៦/២៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងឯកឧត្តម **ថៅ ម៉េងឈាត** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា

ប្រកាសអោយប្រើ

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃធនាគារជាតិ នៃកម្ពុជាដែលរដ្ឋសភាបានអនុម័ត នាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីដូចតទៅ :

ច្បាប់

ស្តីពី

ការរៀបចំ និងការប្រព្រឹត្តទៅ

នៃធនាគារជាតិនៃកម្ពុជា

* * *

ជំពូកទី ១

បទបញ្ញត្តិទូទៅ

មាត្រា ១ : ធនាគារជាតិនៃកម្ពុជា ហៅថា " ធនាគារកណ្តាល " គឺជាស្ថាប័នស្វយ័តសាធារណៈ មានលក្ខណៈជាពាណិជ្ជកម្ម និងឧស្សាហកម្ម ។

មាត្រា ២ : ធនាគារកណ្តាលជានីតិបុគ្គលមានសមត្ថភាពតតិយុត្តិពេញលេញនិងជាអាទិ៍ មានសមត្ថភាពក្នុងការ :

១–អោយប្រាក់ គេខ្ចី ខ្ចីប្រាក់ពីគេនិងចុះកិច្ចសន្យាផ្សេងៗទៀត ។

២–ប្តឹងនិងការពារនៅមុខតុលាការ ។

៣–ធ្វើលទ្ធកម្ម កាន់កាប់និងផ្ទេរចេញនូវចលនទ្រព្យនិងអចលនទ្រព្យ ក្នុងគោលដៅ នៃការ ប្រកបអាជីវកម្មរបស់ខ្លួន ។

មាត្រា ៣: ធនាគារកណ្តាលមានបេសកកម្មចំបងគឺកំណត់និងដឹកនាំនយោបាយរូបិយវត្ថុក្នុងក្រប ខ័ណ្ឌនយោបាយ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅ រក្សាថ្លៃអោយមានស្ថេរភាពសំដៅ បង្កលក្ខណៈងាយស្រួលដើម្បីអោយសេដ្ឋកិច្ចរីក ចំរើន ។

មាត្រា ៤ : ធនាគារកណ្តាលមានសិទ្ធិចេញប្រកាស បទបញ្ជា សារាចរនិងសេចក្តីណែនាំផ្សេងៗ ទៀត ដើម្បីបំពេញបេសកកម្មរបស់ខ្លួននិងដើម្បីអនុវត្តខ្លឹមសារ នៃច្បាប់នេះ ។

មាត្រា ៥ : ធនាគារកណ្តាលត្រូវចេញផ្សាយជាប្រក្រតីនូវគោលដៅនយោបាយរូបិយវត្ថុ(រូបិយ-វត្ថុ ឥណទាន ការប្តូរប្រាក់ អត្រាការប្រាក់) និងស្ថិតិទាក់ទងជាអាទិ៍ដល់បរិមាណ រូបិយវត្ថុ ថ្លៃ ឥណទាន ជញ្ជី ទូទាត់និងការប្តូរប្រាក់ ។

មាត្រា ៦ : ទីស្នាក់ការដើមធនាគារកណ្តាលត្រូវតាំងនៅរាជធានីភ្នំពេញ ។ ធនាគារកណ្តាលអាចបើកសាខា ទីភ្នាក់ងារក្នុងប្រទេសនិងការិយាល័យតំណាងនៅឯបរទេស ក្រោយពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃ ធនាគារកណ្តាល ។

ជំពូកទី ២

មុខងារនិងភារកិច្ចទូទៅ

មាត្រា ៧ : ធនាគារកណ្តាលមានមុខងារនិងភារកិច្ចដូចតទៅ :

១_កំណត់គោលដៅនយោបាយរូបិយវត្ថុដោយពិគ្រោះជាមួយរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌនយោបាយ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ។

២_គ្រិះរិះរក អនុវត្តនិងត្រួតពិនិត្យនយោបាយរូបិយវត្ថុ និងប្តូរប្រាក់អោយសំរេចទៅតាមគោលដៅដែលបានកំណត់ ។

៣_ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ចនិងរូបិយវត្ថុជាប្រក្រតីរួចចេញផ្សាយលទ្ធផលហើយលើកសំណើនិងវិធានការជូនរាជរដ្ឋាភិបាល ។

៤_ផ្តល់ឬដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងគ្រឹះស្ថានឯទៀតដែលពាក់ព័ន្ធដូចជា ស្នងការគណនី គ្រឹះស្ថានជម្រះបញ្ជីជាដើមព្រមទាំងចេញបទបញ្ញានិងត្រួតពិនិត្យគ្រឹះ ស្ថានទាំងនោះ ។

៥_ត្រួតពិនិត្យប្រព័ន្ធទូទាត់ក្នុងព្រះរាជាណាចក្រកម្ពុជានិងកែលំអប្រសិទ្ធភាពនៃការទូទាត់អន្តរធនាគារ ។

៦_ទទួលភារៈផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

៧_ទទួលខុសត្រូវនិងអនុវត្តក្នុងនាមនៃព្រះរាជាណាចក្រកម្ពុជានូវកិច្ចការទាំងឡាយដែលជាលទ្ធផលនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាប័នអន្តរជាតិសាធារណៈ ក្នុងកិច្ចការធនាគារ ឥណទាននូរូបិយវត្ថុ ។

៨_តម្លើងតារាងជញ្ជីងទូទាត់ ។

៩_ចូលរួមក្នុងការគ្រប់គ្រងបំណុលនិងឥណទេយ្យជាមួយប្រទេសក្រៅ ។

១០_ចូលរួមក្នុងការបង្កើតនិងការត្រួតពិនិត្យទីផ្សាររូបិយវត្ថុនិងទីផ្សារហិរញ្ញវត្ថុ ។

១១_ផ្តល់ ឬ ដកហូតអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានដែលចូលរួមក្នុងអាជីវកម្មទីផ្សារប្តូរប្រាក់ សង្ការឹម ប័ណ្ណត្បូងថ្ម និងលោហធាតុមានតម្លៃ ព្រមទាំងចេញបទបញ្ជាតឹងត្រួតពិនិត្យគ្រឹះស្ថាន ទាំងនេះ ។

១២_កំណត់អត្រាការប្រាក់ ។

មាត្រា ៨ : ធនាគារកណ្តាលអាចបើកគណនីអោយ :

- ស្ថាប័នរដ្ឋ ឬអង្គភាពរដ្ឋបាលកណ្តាល ដូចជារតនាគារជាតិជាដើម
- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានការអនុញ្ញាតពីធនាគារកណ្តាលអោយធ្វើអាជីវកម្ម
- ធនាគារកណ្តាលបរទេសនិងស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ។

ធនាគារកណ្តាល មិនអាចបើកគណនីអោយសហគ្រាសឧស្សាហកម្ម ឬពាណិជ្ជកម្មបានទេ ទោះជារបស់រដ្ឋក៏ដោយ ។

ជំពូកទី ៣

ស្វ័យភាពនៃធនាគារកណ្តាល

មាត្រា ៩ : ដើម្បីបំពេញបេសកកម្មរបស់ខ្លួន ធនាគារកណ្តាលក្នុងឋានៈជាអ្នកទទួលនូវសិទ្ធិអចិន្ត្រៃយ៍ពីរាជរដ្ឋាភិបាល មានស្វ័យភាពក្នុងការគ្រប់គ្រង តែត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តភារកិច្ចនិងលទ្ធផលដែលសំរេចបានជូនរដ្ឋសភានិងរាជរដ្ឋាភិបាល ។

ទេសាភិបាល នៃធនាគារកណ្តាលអាចចូលរួមនិងបញ្ចេញមតិក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីតាមការអញ្ជើញរបស់រាជរដ្ឋាភិបាល ។ រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចូលរួម និងបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលនៃ ធនាគារកណ្តាល តាមការអញ្ជើញរបស់ក្រុមប្រឹក្សាភិបាលនេះ ។

តាមសំណើរបស់រដ្ឋសភា ទេសាភិបាល ឬសមាជិកក្រុមប្រឹក្សាភិបាលត្រូវបំភ្លឺអំពីនយោបាយនៃធនាគារកណ្តាល ឬអត្ថាធិប្បាយសេចក្តីព្រាងច្បាប់ជូនរដ្ឋសភា ឬគណៈកម្មការជំនាញនៃរដ្ឋសភា ។

មាត្រា ១០ : នៅដំណាច់ឆមាសនីមួយៗ ធនាគារកណ្តាលត្រូវដាក់ជូនរដ្ឋសភានិងរាជរដ្ឋាភិបាលនូវរបាយការណ៍ដោយ ÷

- វាយតម្លៃនូវគោលធំៗនៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និង រៀបរាប់អំពីនយោបាយរូបិយវត្ថុនិងនយោបាយប្តូរប្រាក់ដែលធនាគារកណ្តាលត្រូវអនុវត្តក្នុងឆមាសបន្ទាប់ ឬ ក្នុងរយៈពេលវែងជាងនេះ ។
- ពិនិត្យឡើងវិញនិងវាយតម្លៃការអនុវត្តនយោបាយរូបិយវត្ថុនិងនយោបាយប្តូរ ប្រាក់ដែលមាន ចែងក្នុងរបាយការណ៍ឆមាសមុន ។

មាត្រា ១១: ក្រៅពីរបាយការណ៍ខាងលើ ធនាគារកណ្តាលត្រូវធ្វើរបាយការណ៍តាមការចាំបាច់របស់រដ្ឋសភា និងរាជរដ្ឋាភិបាល ។

ជំពូកទី ៤

ការគ្រប់គ្រងធនាគារកណ្តាល

មាត្រា ១២: ១_អង្គការគ្រប់គ្រងរបស់ធនាគារកណ្តាលគឺក្រុមប្រឹក្សាភិបាល ដែលតទៅនេះ ហៅកាត់ថា ក្រុមប្រឹក្សា ។ ក្រុមប្រឹក្សាត្រូវបានដឹកនាំដោយទេសាភិបាល ។ ក្រុមប្រឹក្សានេះមានសមាជិក ៧រូប គឺទេសាភិបាល ទេសាភិបាលរង និងសមាជិក ៥រូបទៀតដែល ១រូប តំណាងប្រមុខរដ្ឋាភិបាល ១រូបតំណាងអោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូបតំណាងអោយមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច ១រូបតំណាងអោយមជ្ឈដ្ឋានឧត្តមសិក្សា និង ១រូបទៀតតំណាងអោយបុគ្គលិកធនាគារកណ្តាល ។

ក្នុងតំណែងរបស់ខ្លួន ទេសាភិបាលនិងទេសាភិបាលរង មិនអាចជាមន្ត្រីរាជការមិនអាចជាទីប្រឹក្សាអង្គភាពសាធារណៈ មិនអាចជាសមាជិករាជរដ្ឋាភិបាល និង មិនអាចជាសមាជិករដ្ឋសភាទេ ។

ល័ក្ខខ័ណ្ឌខាងលើនេះក៏ត្រូវអនុវត្តចំពោះសមាជិកដទៃទៀតដែរលើកលែងតែតំណាងអោយប្រមុខរាជរដ្ឋាភិបាលនិងតំណាងអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុព្រមទាំង តំណាងមជ្ឈដ្ឋានឧត្តមសិក្សា ដែលម្នាក់ៗអាចរក្សាលក្ខណៈជាមន្ត្រីរាជការបាន ។

២_ក្រុមប្រឹក្សាមានភារកិច្ចជាអាទិ៍ :

_រៀបចំនយោបាយសំរាប់កិច្ចប្រតិបត្តិការរបស់ធនាគារកណ្តាល

_ចេញប្រកាស បទបញ្ជា សារាចរ និងសេចក្តីណែនាំផ្សេងៗដើម្បីគ្រប់គ្រងកិច្ចធនាគារ កណ្តាល

–ចងក្រងបទបញ្ជាផ្ទៃក្នុង
–គាក់តែងលក្ខន្តិកៈបុគ្គលិក
–បង្កើតនាយកដ្ឋាននានារបស់ធនាគារកណ្តាល
–បង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យ
–បង្កើតគណៈកម្មការសំរាប់បណ្តុះបណ្តាលវិជ្ជាជីវៈនៃបុគ្គលិក ។

៣–ទេសាភិបាលមានតួនាទីជាអ្នកដឹកនាំទីមួយនៃធនាគារកណ្តាលនិងទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សា លើកិច្ចការអនុវត្តនយោបាយរបស់ខ្លួន ។ ទេសាភិបាលត្រូវទទួលខុសត្រូវលើការដឹកនាំកិច្ចការធនាគារកណ្តាល និង មានសិទ្ធិអំណាចធ្វើកិច្ចការទាំងឡាយណាដែលមិនបានកំណត់សំរាប់ក្រុមប្រឹក្សានៅក្នុងច្បាប់នេះឬ បទបញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធ ។

ទេសាភិបាលត្រូវតែងតាំងមន្ត្រី បុគ្គលិកនៃធនាគារកណ្តាលនិងលើកសំណើជូនក្រុមប្រឹក្សាក្នុងការកម្រិតប្រាក់បៀវត្ស ព្រមទាំងប្រាក់បំណាច់ផ្សេងៗចំពោះក្របខ័ណ្ឌជាន់ខ្ពស់ ។

៤–ទេសាភិបាលរងមានសិទ្ធិអំណាច និង បំពេញភារកិច្ចទាំងឡាយដែលទេសាភិបាលកំណត់អោយ ។ ក្នុងករណីអវត្តមានរបស់ទេសាភិបាល ទេសាភិបាលរងជំនួសទេសាភិបាល ។

មាត្រា ១៣: ទេសាភិបាលនិងទេសាភិបាលរងត្រូវបានតែងតាំង ផ្លាស់ប្តូរបញ្ឈប់ពីតំណែងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល ។

សមាជិកដទៃទៀត នៃក្រុមប្រឹក្សាត្រូវបានតែងតាំង ផ្លាស់ប្តូរបញ្ឈប់ពីតំណែងដោយអនុក្រឹត្យ ។ សមាជិកទាំងនេះត្រូវបានជ្រើសរើសតាមបញ្ជីរៀបចំដោយទេសាភិបាល ដែលមានឈ្មោះ ៣ នាក់ក្នុងប្រភេទ តំណាងនីមួយៗ ។

មាត្រា ១៤ :១–សមាជិកនៃក្រុមប្រឹក្សាត្រូវជាអ្នកដែលគេទទួលស្គាល់ថាមានបទពិសោធន៍និងកិត្តិនាមក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងមានអាយុមិនលើសពី ៦៥ ឆ្នាំ។ សមាជិកទាំងនោះត្រូវបានតែងតាំងសំរាប់ រយៈពេល ៤ ឆ្នាំ និងអាចត្រូវបានតែងតាំងជាថ្មីបានតែ ១ ដងគត់ ។ ចំពោះក្រុមប្រឹក្សាលើកទី១ ដែលបង្កើតតាមច្បាប់ នេះលើកលែងតែទេសាភិបាល ទេសាភិបាលរងនិងតំណាងអោយបុគ្គលិក ធនាគារកណ្តាល

អាណត្តិរបស់សមាជិក ២រូប ត្រូវចប់ក្នុងរយៈ ២ឆ្នាំក្រោយពីថ្ងៃ តែងតាំងដោយវិធីចាប់ឆ្នោត ។

សមាជិកក្រុមប្រឹក្សានិងគ្រួសារផ្ទាល់មិនអាចចូលហ៊ុនក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុណា មួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារកណ្តាលឡើយ ។

២_សមាជិកនៃក្រុមប្រឹក្សាត្រូវបានបញ្ឈប់ពីតំណែងក្នុងករណី :

ក_ជាប់ទោសពីបទល្មើសព្រហ្មទណ្ឌ បទល្មើសរដ្ឋបាល ឬ ពីបទល្មើសផ្នែកសេដ្ឋកិច្ច ឬ ផ្នែកពាណិជ្ជកម្ម ។

ខ_មានសេចក្តីសំរេចពីក្រុមប្រឹក្សាថាមានប្រព្រឹត្តបំពាននៅលើការហាមឃាត់ដែលចែងក្នុងមាត្រា ១៥ និង ១៦ នៃច្បាប់នេះ ។

គ_អវត្តមានក្នុងការប្រជុំជាប់ៗគ្នា៤ដង លើកលែងតែមានជម្ងឺនិងក្នុងករណីប្រធានស័ក្តិដែលបានការទទួលស្គាល់ពីក្រុមប្រឹក្សា ។

ឃ_លាឈប់ដោយបានសរសេរជាលាយលក្ខណ៍អក្សរ ។

ង_មិនអាចបំពេញភារកិច្ចរបស់ខ្លួនបានដោយបាត់បង់សមត្ថភាពពលកម្ម និងវិបត្តិស្មារតី ។

ច_ធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

៣_ការប្រជុំរបស់ក្រុមប្រឹក្សាត្រូវធ្វើយ៉ាងហោចណាស់ ២ ខែ ម្តង ។

៤_សមាជិកនៃក្រុមប្រឹក្សាត្រូវទទួលកម្រៃក្បាច់វត្តមានដែលក្រុមប្រឹក្សាជាអ្នកកំណត់

៥_ទេសាភិបាលនិងទេសាភិបាលរងទទួលប្រាក់តម្លៃការជាមូលដ្ឋានពីធនាគារកណ្តាលស្មើនឹង សមាជិកនៃរាជរដ្ឋាភិបាល ។

មាត្រា ១៥ : ១_មិនអនុញ្ញាតអោយអ្នកដឹកនាំ បុគ្គលិក ឬសមាជិកណាម្នាក់នៃក្រុមប្រឹក្សារបស់ធនាគារ កណ្តាល :

_ ទាញយកតាមរយៈធនាគារកណ្តាលនូវផលប្រយោជន៍ទាក់ទងនឹងផ្នែកពាណិជ្ជកម្ម ហិរញ្ញវត្ថុ កសិកម្ម ឧស្សាហកម្ម ឬ ផ្នែកផ្សេងៗទៀត ។

_ ទទួលយកដើម្បីផលប្រយោជន៍ទាំងនេះ នូវការណែនាំដែលពាក់ព័ន្ធដល់ភារកិច្ចដែលខ្លួនត្រូវបំពេញដូចមានចែងក្នុងច្បាប់នេះ

_ ទទួលធ្វើការងារណាដែលផ្ទុយពីភារកិច្ចរបស់ខ្លួន

- ទទួលអំណោយ ឬលាភសក្ការៈសំរាប់ខ្លួនឯងផ្ទាល់ ឬសំរាប់បុគ្គលជិតស្និទ្ធជាមួយខ្លួនដែលជាគ្រួសារផ្ទាល់ក្តី ជាភាគីពាណិជ្ជកម្ម ឬហិរញ្ញវត្ថុក្តីដោយលំអៀងនូវភាពស្មោះត្រង់ក្នុងការបំពេញភារកិច្ច ។

២_សមាជិកទាំងអស់នៃក្រុមប្រឹក្សាត្រូវរាយការណ៍អោយបានសព្វគ្រប់ជូនទៅក្រុមប្រឹក្សាអំពីផលប្រយោជន៍សំខាន់ៗផ្នែកពាណិជ្ជកម្ម ហិរញ្ញវត្ថុ កសិកម្ម ឧស្សាហកម្ម ឬរបរអាជីវកម្មផ្សេងទៀតដែលខ្លួន ឬ គ្រួសារផ្ទាល់មានដោយចំពោះឬដោយប្រយោល ហើយពុំមានសិទ្ធិបោះឆ្នោតលើបញ្ហាទាំងឡាយណា ដែលពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ខ្លួនឡើយ ។ ប៉ុន្តែអាចចូលរួមដើម្បីបំពេញចំនួនកូរ៉ុមក្នុងអង្គប្រជុំ ដែលត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ។

មាត្រា ១៦: អ្នកដឹកនាំ បុគ្គលិកនិងសមាជិកនៃក្រុមប្រឹក្សារបស់ធនាគារកណ្តាលមិនត្រូវផ្តល់អោយអ្នកដទៃ នូវពត៌មានដែលទាក់ទងនឹងការសំងាត់វិជ្ជាជីវៈដែលខ្លួនបានទទួលក្នុងពេលបំពេញភារកិច្ចឡើយ លើកលែង តែក្នុងករណីចាំបាច់ដែលច្បាប់អនុញ្ញាត ឬមានការបង្គាប់ពីតុលាការ ។

ជំពូកទី ៥

ដើមទុន ការប្រើប្រាស់ប្រាក់ចំណេញនិងថវិកា

មាត្រា ១៧ :១_ធនាគារកណ្តាលត្រូវបានអនុញ្ញាតអោយមានដើមទុនដែលកំរិតដោយអនុក្រឹត្យ។ ដើមទុន នេះអាចកែប្រែបានតាមពេលវេលាចាំបាច់ ។ ដើមទុនទាំងមូលត្រូវបានចុះបញ្ជីនិងកាន់កាប់ផ្តាច់មុខដោយរាជរដ្ឋាភិបាល និង មិនអាចផ្ទេរឬដាក់អោយជាប់ល័ក្ខខ័ណ្ឌអ្វីឡើយ ។

២_នៅពេលដែលទ្រព្យសកម្មពិតក្នុងតារាងតុល្យការរបស់ធនាគារកណ្តាលថយចុះក្រោមចំនួនទ្រព្យអកម្ម រាជរដ្ឋាភិបាលត្រូវប្រគល់ជូនធនាគារ កណ្តាលនូវមូលប័ត្ររដ្ឋ ដើម្បីបំពេញឱនភាពនោះក្នុងកំឡុង ៦០ថ្ងៃ ក្រោយពីពេលចេញផ្សាយតារាងតុល្យការរបស់ធនាគារកណ្តាល ។ មូលប័ត្ររដ្ឋជាប័ណ្ណ អាចធ្វើអន្តរការបានដោយគិតការប្រាក់តាមអត្រាបុនហិរញ្ញប្បទាន ។

មាត្រា ១៨ : លទ្ធផលជាមូលដ្ឋាននៃការិយបរិច្ឆេទនីមួយៗរបស់ធនាគារកណ្តាលត្រូវបានគណនា ក្រោយពីបានដកចំណាយប្រតិបត្តិការប្រចាំការិយបរិច្ឆេទនោះនិងក្រោយពីបានដកទុកសំរាប់ :

១_ទាយជ្ជទានដល់គណនីសិរិធានធនសំរាប់ហានិភ័យនិងការស្រុតចុះតម្លៃនិងដល់គណនីរំលស់ទ្រព្យសកម្ម ។

២_សិរិធានធនដល់មូលនិធិសោធនដែលកំណត់ដោយក្រុមប្រឹក្សា ។

៣_ប្រាក់បំរុងទូទៅស្មើនឹង ២០% (ម្ភៃភាគរយ) លើលទ្ធផលក្រោយពីដកក្នុងចំណុច ១និង ២ នៃមាត្រានេះ ។

៤_ប្រាក់បំរុងសំរាប់សងថ្លៃមូលប័ត្រទាំងឡាយដែលធនាគារកណ្តាលបានទទួល ។

៥_មូលនីធិសំរាប់វិនិយោគសម្ភារបស់ធនាគារកណ្តាលដែលកំណត់ដោយក្រុមប្រឹក្សា ។

មាត្រា ១៩ : ប្រាក់ចំណេញសុទ្ធត្រូវបង់ចូលថវិកាជាតិក្រោយពីបានដកចេញ :

_៥% (ប្រាំភាគរយ) សំរាប់រង្វាន់បុគ្គលិក ដោយមិនគិតក្រុមប្រឹក្សា ។

_០,៥% (សូន្យក្បៀសប្រាំភាគរយ) សំរាប់សមាជិកក្រុមប្រឹក្សា ។

មាត្រា ២០: គម្រោងចំណាយទាំងអស់របស់ធនាគារកណ្តាលត្រូវចងក្រងក្នុងថវិកាប្រចាំឆ្នាំរបស់ខ្លួនដែលត្រូវអនុម័តដោយក្រុមប្រឹក្សាហើយផ្ញើជូនរាជរដ្ឋាភិបាលនិងរដ្ឋសភាដើម្បីជាពត៌មាន ។

ជំពូកទី ៦

សម្ព័ន្ធការផ្នែកហិរញ្ញវត្ថុជាមួយអង្គភាពសាធារណៈ

មាត្រា ២១ : ១_ធនាគារកណ្តាលទទួលប្រាក់បញ្ញើផ្តាច់មុខជារូបិយវត្ថុជាតិពីរតនាគារជាតិ ។ ធនាគារកណ្តាលទទួលប្រាក់ពីរតនាគារជាតិ ហើយចេញជូសនូវទឹកប្រាក់ដែលរតនាគារជាតិត្រូវចំណាយ ។

ធនាគារកណ្តាលត្រូវកំណត់ជាមួយនឹងរតនាគារជាតិនូវកម្រៃដែលត្រូវបង់ជូនធនាគារកណ្តាល លើរាល់ប្រតិបត្តិការដែលត្រូវអនុវត្ត ។

២_ចំណូលជារូបិយប័ណ្ណរបស់ធនាគារជាតិត្រូវលក់អោយធនាគារកណ្តាល ហើយធនាគារ កណ្តាលត្រូវបញ្ចូលទឹកប្រាក់ជារៀលក្នុងគណនីតែមួយរបស់ធនាគារជាតិ ដោយគិតតាមអត្រាប្តូរប្រាក់ប្រ ចាំថ្ងៃ ។

មាត្រា ២២ : ធនាគារកណ្តាលជាទីប្រឹក្សារបស់រាជរដ្ឋាភិបាលក្នុងវិស័យរូបិយវត្ថុនិងហិរញ្ញវត្ថុ ។ ធនាគារកណ្តាលមានភារកិច្ចក្នុងការផ្តល់ពត៌មាននិងយោបល់ជូនរាជរដ្ឋាភិបាលអំពីបញ្ហាទាំងឡាយដែលមានអានុភាពក្នុងការធ្វើអោយសំរេចគោលដៅនយោបាយ នៃហិរញ្ញវត្ថុ ។

មាត្រា ២៣ : ១_ធនាគារកណ្តាល ត្រូវជួយគ្រប់គ្រងក្នុងការខ្ចីប្រាក់របស់រាជរដ្ឋាភិបាល ឬ អង្គភាព សាធារណៈដោយធ្វើប្រតិបត្តិការលើមូលប័ត្រជាអាទិ៍ ជូនយោបល់លើកាលបរិច្ឆេទនៃ ការបោះផ្សាយមូលប័ត្រនិងជំរុញទីផ្សាររូបិយវត្ថុនិងទីផ្សារ ហិរញ្ញវត្ថុអោយរីកចំរើន ។

២_ធនាគារកណ្តាលអាចទទួលធ្វើជាអាណត្តិគាហករបស់រាជរដ្ឋាភិបាល ឬ របស់អង្គភាពសាធារណៈចំពោះប្រតិបត្តិការដូចខាងក្រោមនេះ :

_ការទិញ_លក់មូលប័ត្រដែលបោះផ្សាយដោយរាជរដ្ឋាភិបាលឬអង្គភាពសាធារណៈ ព្រមទាំងកិច្ចការជាភ្នាក់ងារជាគណនេយ្យ ដើម្បីចុះបញ្ជីនិងផ្ទេរនូវមូលប័ត្រនោះ

_ការទូទាត់សងដើមនិងការប្រាក់ព្រមទាំងកម្រៃផ្សេងៗលើមូលប័ត្រទាំងនោះ ។

៣_ធនាគារកណ្តាលត្រូវកំណត់ជាមួយរាជរដ្ឋាភិបាល ឬ អង្គភាពសាធារណៈ អំពីកម្រៃដែលត្រូវបង់ជូនធនាគារកណ្តាលលើរាល់ប្រតិបត្តិការដែលមានចែងក្នុងចំណុច ២ នៃមាត្រានេះ ។

មាត្រា ២៤: ធនាគារកណ្តាលមិនត្រូវផ្តល់ឥណទានដោយផ្ទាល់ ឬ ដោយប្រយោលដល់រាជរដ្ឋាភិបាលឡើយ ជាពិសេសដោយទិញយកមូលប័ត្រដែលបោះផ្សាយដំបូង ឬមូលប័ត្រដែលធានាដោយរាជរដ្ឋាភិបាល ឬ ដោយអង្គភាពសាធារណៈ លើកលែងតែករណីស្របទៅនឹងបទបញ្ញត្តិនានាក្នុងជំពូកនេះ ។

មាត្រា ២៥: ធនាគារកណ្តាលអាចផ្តល់ឥណទានដែលមានកាលវសានមិនហួសពី ៣ខែ ជូនទៅធនាគារ ជាតិដោយគិតការប្រាក់តាមអត្រាបុនហិរញ្ញប្បទាន :

១_រាល់ប្រតិបត្តិការឥណទានត្រូវមានកិច្ចព្រមព្រៀងរវាងធនាគារកណ្តាលនិងអ្នកខ្ចី ដែលត្រូវមានបញ្ជាក់ទឹកប្រាក់ឥណទាន កាលវសាននិងអត្រាការប្រាក់ ។

២_ប្រតិបត្តិការឥណទានត្រូវធ្វើអោយមានយថាភាពដោយប្រគល់ជូនធនាគារកណ្តាល នូវមូលប័ត្ររដ្ឋដែលអាចធ្វើអន្តរការបាន ។

៣_ចំនួនទឹកប្រាក់សរុបនៃឥណទាននិងមូលប័ត្រដែលមានស្របតាមមាត្រា ២៤ នៃច្បាប់នេះ ក្នុងការិយបរិច្ឆេទនីមួយៗមិនត្រូវអោយលើសពី ១០% (ដប់ភាគរយ) នៃចំណុចធម្មតានៃថវិកាជាតិ ក្នុងការិយបរិច្ឆេទនាឆ្នាំមុនឡើយ ដោយមិនគិតជំនួយ និងចំណូលពីការលក់ទ្រព្យសម្បត្តិ ។

មាត្រា ២៦: នៅក្នុងក្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការផ្សារចំហឬកិច្ចប្រតិបត្តិការអប្បហារ ឬឥណទាន ជាមួយនឹងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារកណ្តាលអាចលក់ ទិញ ទទួល ឬដាក់បញ្ចាំ នៃមូលប័ត្ររដ្ឋដែលត្រូវបានគេបោះផ្សាយជាសាធារណៈពីមុនមក ហើយដែលត្រូវផុតកំណត់សងក្នុងកំឡុង ៩០ថ្ងៃ ។

មាត្រា ២៧ : ជារៀងរាល់ឆ្នាំរាជរដ្ឋាភិបាលត្រូវពិគ្រោះជាមួយធនាគារកណ្តាលសិន មុននឹងសំរេចថវិកាជាតិជាស្ថាពរដើម្បីកំណត់នូវចំនួនទឹកប្រាក់ឥណទានសរុបដែលរាជរដ្ឋាភិបាល និងអង្គភាពសាធារណៈនានាអាចត្រូវការពីធនាគារកណ្តាលក្នុងកម្រិតដូចមានចែងក្នុង មាត្រា ២៥ នៃច្បាប់នេះ ។

មាត្រា ២៨: ធនាគារកណ្តាលចូលរួមក្នុងការគ្រប់គ្រងបំណុលសាធារណៈក្នុង និង ក្រៅប្រទេស ដោយរាប់បញ្ចូលទាំងលិខិតធានារ៉ាប់រងចេញជូនឥណទាយកផង ។

ជំពូកទី ៧

របបនិងនយោបាយប្តូរប្រាក់

មាត្រា ២៩: ធនាគារកណ្តាលត្រូវកំអត់ និងអនុវត្តរបប និងនយោបាយប្តូរប្រាក់ នៃព្រះរាជាណាចក្រកម្ពុជាដោយពិគ្រោះជាមួយរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ចហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៣០ :១_ធនាគារកណ្តាលត្រូវរក្សានិងគ្រប់គ្រងទុនបំរុងផ្លូវការក្រៅប្រទេសដែលរួមមាន ÷

_មាសរូបិយវត្ថុ

– រូបិយប័ណ្ណដែលមានទ្រង់ទ្រាយជាក្រដាស ឬ ជាកាសនិងសមតុល្យធនាគារនៅបរទេស

– ធនធានជាទុនបំរុងដែលអន្តរជាតិទទួលស្គាល់ជាអាទិ៍មាន :

– រូបិយប័ណ្ណដែលទិញពីមូលនីធិរូបិយវត្ថុអន្តរជាតិយកក្នុងផ្នែកបំរុង

– ធនធានជាសិទ្ធិដកពិសេស អេស.ឌី.អរ (S D R) របស់ព្រះរាជាណាចក្រកម្ពុជា

– រូបិយាណត្តិនិងប័ណ្ណសងតាមបញ្ជាដែលមានកំណត់ជារូបិយប័ណ្ណ ហើយត្រូវសងនៅក្រៅប្រទេស ។

– ប័ណ្ណរតនាគារដែលបោះផ្សាយដោយរដ្ឋាភិបាលបរទេស

– មូលប័ត្រដែលបោះផ្សាយឬធានាដោយរដ្ឋាភិបាលបរទេសឬស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា

២– ធនាគារកណ្តាលត្រូវរក្សាទុនបំរុងក្រៅប្រទេសអោយនៅកំរិតគ្រប់គ្រាន់ដើម្បីធានាដល់ប្រតិបត្តិការអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

៣– កាលណាទុនបំរុងផ្លូវការក្រៅប្រទេសមានការថយចុះ ឬមានភាពដែលអាចថយចុះដល់កម្រិតខ្វះខាត ធនាគារកណ្តាលត្រូវដាក់ជូនដល់រាជរដ្ឋាភិបាលនូវរបាយការណ៍ស្តីពីមូលហេតុនៃបញ្ហា និង វិធានការដើម្បីកែសម្រួល ។ របាយការណ៍នេះត្រូវធ្វើជាប្រចាំរហូតដល់ស្ថានភាពថយចុះខាងលើត្រូវបានដោះស្រាយរួចជាស្រេច ។

៤– ធនាគារកណ្តាលជាអ្នកទទួលបន្ទុកថែរក្សាធនធានផ្លូវការក្រៅប្រទេសរបស់ព្រះរាជាណាចក្រកម្ពុជា ហើយមានសិទ្ធិជ្រើសរើសអាណត្តិគាហកដែលជាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ធនាគារកណ្តាល ឬធនាគារពាណិជ្ជកម្មបរទេសដើម្បីកាន់កាប់ជំនួស ។

មាត្រា ៣១: ១– ធនាគារកណ្តាលត្រូវកំណត់អត្រាប្តូរប្រាក់នៃរូបិយវត្ថុជាតិអោយមាននិយតភាព ។ ដូច្នេះ ធនាគារកណ្តាលមានសិទ្ធិជាអាទិ៍ :

– ធ្វើអាជីវកម្មលើមាសជាកាសឬជាដុំនិងលើលោហធាតុឬត្បូងថ្មមានតម្លៃផ្សេងទៀត

– ធ្វើអាជីវកម្មលើរូបិយប័ណ្ណដោយប្រើឧបករណ៍នានាដែលធនាគារិកធ្លាប់ប្រើជាទូទៅ

– ធ្វើអាជីវកម្មលើប័ណ្ណរតនាគារឬលើមូលប័ត្រផ្សេងទៀត ដែលបោះផ្សាយឬធានាដោយ រដ្ឋាភិបាលបរទេសឬស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិ

_បើក និង កាន់កាប់គណនីធនាគារពាណិជ្ជកម្មឬស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិនៅឯ បរទេស

_បើក និង កាន់កាប់គណនី និងធ្វើសកម្មភាពជាភ្នាក់ងារឬជាអ្នកទាក់ទងជំនួសមុខធនាគារកណ្តាលបរទេស រដ្ឋាភិបាលបរទេស ទីភ្នាក់ងាររដ្ឋាភិបាលបរទេសនិងស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិ នានា

_ កំណត់អត្រាទិញ លក់រូបិយប័ណ្ណនានា

_ កម្រិតស្ថានភាពរូបិយប័ណ្ណនៃធនាគារពាណិជ្ជនិងទីកន្លែងប្តូរប្រាក់ដែលមិនមែនជាធនាគារ

_ ចេញបទបញ្ជាដែលពាក់ព័ន្ធលើការប្តូរប្រាក់និងអាជីវកម្មលើមាស លោហធាតុនិងត្បូងថ្មមានតម្លៃ

_ប្រកាសអត្រាប្តូររវាងប្រាក់រៀលនិងរូបិយប័ណ្ណផ្សេងៗ

_ចូលរួមក្នុងកិច្ចព្រមព្រៀងរូបិយវត្ថុអន្តរជាតិជំនួសមុខអោយរដ្ឋ

២_ធនាគារកណ្តាលមិនអាចផ្តល់អោយអ្នកដទៃនូវលិខិតធានាអត្រាប្តូរប្រាក់ទៅអនាគត ហើយមិនអាចអនុញ្ញាត ឬមិនត្រូវប្រើពហុអត្រាឡើយ ។

មាត្រា ៣២ : ១_ប្រាក់តម្លៃលើសសុទ្ធក្នុងពេលបិទបញ្ជីម្តងៗដែលកើតមានឡើងពីការប្រែប្រួលតម្លៃទ្រព្យសកម្មនិងទ្រព្យអកម្មនៃធនាគារកណ្តាលដែលកត់ត្រាជារូបិយប័ណ្ណ ឬឯកតាគណនីឯទៀតក្រៅពីរូបិយវត្ថុជាតិ ត្រូវចុះជាឥណទាននៅក្នុងគណនីទុនបំរុងពិសេស ។

២_ប្រាក់តម្លៃខ្វះសុទ្ធក្នុងពេលបិទបញ្ជីម្តងៗដែលកើតមានឡើងពីការប្រែប្រួលដូចខាងលើនេះ ត្រូវកត់ត្រាបញ្ចេញពីសមតុល្យឥណទាយីនៃគណនីទុនបំរុងពិសេស ហើយបើសមតុល្យនោះមានបរិមាណមិនគ្រប់គ្រាន់ ដើម្បីទូទាត់ប្រាក់ខ្វះទាំងនោះទេ រតនាគារជាតិត្រូវចេញមូលប័ត្រដែលអាចធ្វើអន្តរការបាន ដោយគិតការប្រាក់តាមអត្រាបុនហិរញ្ញប្បទានទៅអោយធនាគារកណ្តាលដើម្បីបង្គ្រប់ឱនភាព ។

៣_ទាំងប្រាក់តម្លៃលើសសុទ្ធ ទាំងប្រាក់តម្លៃខ្វះសុទ្ធដែលចែងក្នុងមាត្រានេះមិនត្រូវគិតចូល ក្នុងតារាងប្រតិលាភប្រចាំឆ្នាំរបស់ធនាគារកណ្តាលឡើយ ។

៤_រាល់សមតុល្យឥណទាយីក្នុងគណនីទុនបំរុងពិសេស នៅចុងការិយបរិច្ឆេទនៃធនាគារកណ្តាល ត្រូវប្រើសំរាប់សងមូលប័ត្រដែលត្រូវបានបោះផ្សាយដូចមានចែងក្នុងចំណុច ២នៃមាត្រានេះ ។

៥_សមតុល្យគណនីទុនបំរុងពិសេសនេះមិនត្រូវមានការតម្រឹមតម្រង់ឡើយ លើកលែងតែអនុលោមតាមមាត្រានេះ ។

ជំពូកទី ៨

សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

មាត្រា ៣៣ : ធនាគារកណ្តាលត្រូវទទួលខុសត្រូវផ្តាច់មុខក្នុងការផ្តល់ឬដកហូតអាជ្ញាប័ណ្ណនិងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានឯទៀតដូចមានចែងក្នុងមាត្រា ៧នៃច្បាប់នេះដោយ :

១_ចេញប្រកាស បទបញ្ជានិងការណែនាំផ្សេងៗព្រមទាំងចាត់វិធានការចាំបាច់ដើម្បីធ្វើអោយសំរេចមុខងារដែលមានចែងក្នុងជំពូកទី ២ នៃច្បាប់នេះ ដោយអនុវត្តបទដ្ឋាននៃការផ្តល់ឬដកហូតអាជ្ញាប័ណ្ណ និង ត្រួតពិនិត្យព្រមទាំងមធ្យោបាយសមស្រប ។

២_ចាត់តាំងបុគ្គលិករបស់ខ្លួន ឬបុគ្គលដទៃទៀតដែលមានសមត្ថភាពអោយត្រួតពិនិត្យជានិច្ចកាលបើលិខិតស្នាមនិងចុះធ្វើអធិការកិច្ចដល់កន្លែង ព្រមទាំងពិនិត្យបញ្ជីការចុះបញ្ជីនិងឯកសារផ្សេងៗរបស់ គ្រឹះស្ថានទាំងនោះ ។

៣_តម្រូវអោយអភិបាល ឬបុគ្គលិកគ្រឹះស្ថានទាំងនោះ ផ្តល់ដល់ធនាគារកណ្តាលនូវពត៌មាន នានា សំរាប់ធ្វើការត្រួតពិនិត្យនិងកែតម្រូវ ។

៤_ប្តឹងទៅតុលាការឬដាក់កម្មវិបាកតាមច្បាប់ជាធរមាន ប្រសិនបើមានការប្រព្រឹត្តិល្មើសដោយ គ្រឹះស្ថាន ឬដោយអភិបាលបុគ្គលិករបស់គ្រឹះស្ថាននោះ :

_បំពានបទបញ្ញត្តិនៃច្បាប់ជាធរមាន ឬបទបញ្ជារបស់ធនាគារកណ្តាល

_ការខ្វះខាតក្នុងការបំពេញកាតព្វកិច្ចផ្សេងៗ

_មិនគោរពវិធានការនយោបាយរូបិយវត្ថុឬវិធានការប្រុងប្រយ័ត្ននានាដែលបានកំណត់ ។

មាត្រា ៣៤: ធនាគារកណ្តាលមានសិទ្ធិបើកគណនីនិងទទួលប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងផ្តល់ការប្រាក់ និងយកកម្រៃដែលធនាគារកណ្តាល ជាអ្នកកំណត់ ។

មាត្រា ៣៥: ១_ធនាគារកណ្តាលចេញបទបញ្ជាដោយផ្សព្វផ្សាយឬជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ទីស្នាក់ការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីតម្រូវអោយគ្រឹះស្ថានទាំងនោះតំកល់ទុនបំរុងកាតព្វកិច្ច ។ ទុនបំរុងនេះត្រូវរក្សាជាសាច់ប្រាក់ក្នុងបេឡារបស់ខ្លួនឬជាប្រាក់បញ្ញើពិសេសក្នុងគណនីចរន្តនៅធនា-គារកណ្តាល ។

២_ធនាគារកណ្តាលតម្រូវមេគុណទុនបំរុងដូចគ្នាចំពោះកិច្ចសន្យាសទិស ។ ចំនួនទឹកប្រាក់ទុនបំរុងតំកល់ទុករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានកំណត់ដោយយោលទៅតាមប្រាក់បញ្ញើ និង កិច្ចសន្យាសទិសផ្សេងៗទៀតដែលគ្រឹះស្ថានធ្វើជាមួយអតិថិជន ។

រាល់ការកំណត់ឬការបង្កើនមេគុណទុនបំរុងកាតព្វកិច្ចនឹងចូលជាធរមាន ១ខែចាប់ ពីពេល ដែលគ្រឹះស្ថាននោះបានទទួលដំណឹងជាលាយលក្ខណ៍អក្សរ ។

ធនាគារកណ្តាលអាចលើកលែងការតំកល់ទុនបំរុងជូនគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុប្រភេទខ្លះ ។

៣_ធនាគារកណ្តាលដាក់វិន័យដោយយកកម្រៃជើងសាក្នុងមួយថ្ងៃដែលល្មើសស្មើនឹង ១/១០(មួយភាគដប់) នៃអត្រាបុនហិរញ្ញប្បទានចុងក្រោយរបស់ធនាគារកណ្តាល លើគ្រឹះស្ថានទាំងឡាយណាដែលមិនគោរពទុនបំរុងកាតព្វកិច្ច ។ កម្រៃជើងសាទាំងនេះអាចដកយកពីសមតុល្យនៃគណនីរបស់គ្រឹះស្ថាននោះដែលមាន បើកនៅធនាគារកណ្តាល ។

មាត្រា ៣៦ : ១_ធនាគារកណ្តាលត្រូវកំណត់បែបបទ ហើយទិញលក់ជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬធ្វើអប្បហារ បុនប្បហារ ក៏ដូចជាធ្វើកិច្ចប្រតិបត្តិការប៉ង់ស្យុងនូវ :

ក_រូបិយាណត្តិឬប័ណ្ណសងតាមបញ្ជាដែលបោះផ្សាយ ឬធ្វើឡើងសំរាប់ផ្នែកពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្មជាយថាភូតដោយមានហត្ថលេខាសាធនីយពីរយ៉ាងតិច ក្នុងនោះយ៉ាងហោចណាស់ ត្រូវមានហត្ថលេខាមួយជារបស់ធនាគារពាណិជ្ជ ដែលមាន

កាលវសាន ៩០ថ្ងៃ ចាប់ពីថ្ងៃដែលបានទទួល ក៏ប៉ុន្តែរូបិយាណត្តិនិងប័ណ្ណសង តាមបញ្ជាដែលចេញឬធ្វើឡើងសំរាប់ហិរញ្ញប្បទាន ផលិតកម្មឬពាណិជ្ជកម្មធញ្ញជាតិ តាមរដូវកាលអាចមានកាលវសាន ២១០ថ្ងៃ គិតពីថ្ងៃចេញផ្សាយ ។

ខ_មូលប័ត្ររដ្ឋដែលបានចេញផ្សាយជាសាធារណៈនិងមានកាលវសាន ៩០ថ្ងៃ គិតពីថ្ងៃ ដែលបានធ្វើលទ្ធកម្ម ។

គ_មូលប័ត្រឥណទេយ្យឯកជនដែលអាចជួញដូរបានលើទីផ្សាររូបិយវត្ថុព្រមទាំងឥណទេយ្យឯកជនរបស់ធនាគារ ដែលមានហត្ថលេខាសាធនីយនិង ដែលមានចុះនៅក្នុងបញ្ជីដោយទទួលស្គាល់ ដោយក្រុមប្រឹក្សា ។

ឃ_មូលប័ត្ររបស់ធនាគារកណ្តាលផ្ទាល់ ។

២_ធនាគារកណ្តាលត្រូវកំណត់និងចេញផ្សាយនូវអត្រាអប្បបរមាសំរាប់ធ្វើបុនអប្បហារបុរេប្រទាន ទទួលប៉ង់ស្យុង ឬអោយខ្ចី ។ ធនាគារកណ្តាលអាចកំណត់អត្រានិងពិដានអតិបរមាខុសៗគ្នា សំរាប់ ប្រតិបត្តិការ ឬកាលវសានផ្សេងៗគ្នា ។

មាត្រា ៣៧: ធនាគារកណ្តាលអាចផ្តល់បុរេប្រទានលើគណនីចរន្តដល់ធនាគារពាណិជ្ជកម្ម ដែលធានាដោយមូលប័ត្ររដ្ឋ ឬមូលប័ត្រធានាដោយរដ្ឋ ។

មាត្រា ៣៨: ១_គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ធនាគារកណ្តាលដែលប្រកាសជារួមឬដោយឡែក ស្តីពីតារាងតុល្យការ ការសន្យាក្រៅតារាងតុល្យការនិង គណនីអាជីវកម្មដែលទាក់ទងទៅនឹង :

_ដើមទុនអប្បបរមា

_ចំនួនទឹកប្រាក់អប្បបរមានៃមូលនីធិសុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្ទាល់

_ការហាមឃាត់ ការដាក់កំរិត ល័ក្ខខ័ណ្ឌ បញ្ញត្តិផ្សេងៗ

២_គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើសកម្មភាពដូចគ្នានិងមានស្ថានភាពហិរញ្ញវត្ថុដូចគ្នា ត្រូវស្ថិតនៅក្រោមបញ្ញាដូចគ្នា ។

មាត្រា ៣៩: ១_គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវផ្តល់ជូនទៅធនាគារកណ្តាលនូវពត៌មានឬទិន្នន័យដែល ធនាគារកណ្តាលសុំស្នើដើម្បីបំពេញមុខងាររបស់ខ្លួន ។

២_ក្នុងក្របខ័ណ្ឌរក្សាការសម្ងាត់វិជ្ជាជីវៈ ធនាគារកណ្តាលអាចបោះពុម្ពផ្សាយទាំងស្រុងឬ មួយផ្នែកនូវពត៌មានទាំងនោះឬទិន្នន័យរួមតាមប្រភេទគ្រឹះស្ថាន ធនាគារនិងហិរញ្ញវត្ថុ ឬតាមប្រភេទសកម្មភាព របស់គេ ។

៣_ធនាគារកណ្តាលទទួលរ៉ាប់រងកំពស់សេវាអន្តរធនាគារដូចជាធ្វើមជ្ឈការនៃហានិភ័យ និង ការមិនសងបំណុលជាដើម ។

មាត្រា ៤០: ក្នុងកិច្ចសហប្រតិបត្តិការជាមួយធនាគារពាណិជ្ជ ធនាគារកណ្តាលត្រូវបង្កើតសភាផាត់ទាត់មួយ សំរាប់បំរើការទូទាត់អន្តរធនាគារអោយឆាប់រហ័សនិងមានប្រសិទ្ធភាព ។

ជំពូកទី ៩

រូបិយវត្ថុ

មាត្រា ៤១: ឯកតារូបិយវត្ថុរបស់កម្ពុជាគឺរៀល ។ មួយរៀលស្មើនឹងដប់កាក់ ។ មួយកាក់ស្មើនឹងដប់សេន។ សញ្ញាសំគាល់ប្រាក់រៀលគឺអក្សរ (៛) ។

មាត្រា ៤២: ធនាគារកណ្តាលមានសិទ្ធិផ្តាច់មុខក្នុងការបោះផ្សាយក្រដាសប្រាក់និងកាសជារៀល កាក់និង សេន ។

មាត្រា ៤៣: ១_ក្នុងពេលដែលមិនបានដកចេញពីចរាចរទេនោះ ក្រដាសប្រាក់និងកាសដែលបោះផ្សាយ ដោយធនាគារកណ្តាលគឺជារូបិយវត្ថុមានតម្លៃនីត្យានុកូល ក្នុងព្រះរាជាណាចក្រកម្ពុជានិងមានតេជានុភាពធ្វើ សេរីកាគ្មានព្រំដែនចំពោះក្រដាសប្រាក់ និងមានព្រំដែនចំពោះកាសក្នុងល័ក្ខខ័ណ្ឌកំណត់ដោយធនាគារ កណ្តាល ។

២_ការទូទាត់ណាដែលមានចំនួនទឹកប្រាក់លើសពីការកំណត់របស់ធនាគារកណ្តាល អាចឬត្រូវ តែធ្វើតាមលេខនា ។

មាត្រា ៤៤: ១_ធនាគារកណ្តាលជាអ្នកទទួលបន្ទុកក្នុងការបោះពុម្ពក្រដាសប្រាក់ ចាក់ពុម្ពកាស និងការងារ ពាក់ព័ន្ធឯទៀតដូចជាការធានាសន្តិសុខក្នុងការថែរក្សានិង ចលនាក្រដាសប្រាក់និងកាសដែលមិនទាន់បញ្ចេញផ្សាយ ការធានាថែរក្សានិងការបំផ្លាញចោលនូវពេលចាំបាច់នូវបណ្តាពុម្ពក្រដាសប្រាក់ និងកាសដែលដក ចេញពីចរាចរ ។

២_ធនាគារកណ្ដាលត្រូវកំណត់ដោយបទបញ្ជានូវលក្ខណៈផ្សេងៗ តម្លៃ ទំហំ ទម្ងន់ គំរូ និងលក្ខណៈរូបភាពផ្សេងៗទៀតរបស់ក្រដាសប្រាក់ដែលត្រូវបោះពុម្ព និងកាក់ដែលត្រូវចាក់ពុម្ព ។

មាត្រា ៤៥: ធនាគារកណ្ដាលមានសិទ្ធិសំរេចប្រកាសប្តូរ ក្រោយពីមានការយល់ព្រមពីរាជរដ្ឋាភិបាលដើម្បីដកចេញពីចរាចរនូវក្រដាសប្រាក់ និង កាក់ដែលបានបោះផ្សាយរួចហើយ ។ ធនាគារកណ្ដាលចំណាយសងតាមតម្លៃនៃក្រដាសប្រាក់ឬកាក់ទាំងនោះដោយប្តូរនឹងក្រដាសប្រាក់ឬកាក់ផ្សេងទៀតដែលខ្លួនបានបោះផ្សាយ ។ សេចក្តីសំរេច នេះត្រូវមានទំរង់ជាបទបញ្ជារបស់ធនាគារកណ្ដាលហើយត្រូវបញ្ជាក់ច្បាស់អំពីរយៈពេលនិងទីតាំងដែលត្រូវប្តូរក្រដាសប្រាក់និងកាក់ទាំងនោះ ។

មាត្រា ៤៦: នៅពេលចប់រយៈកាលប្តូរក្រដាសប្រាក់និងកាក់ដែលបានចែងក្នុងមាត្រា ៤៥ :

១_ក្រដាសប្រាក់និងកាក់ប្រមូលចូលដែលបានមកពីការប្តូរត្រូវតែលែងមានតម្លៃនីត្យានុកូល ។

២_ចំនួនទឹកប្រាក់ជាក្រដាសនិងជាកាក់សរុបដែលបានប្រកាសអោយមកប្តូរ តែមិនបានយកមកប្តូរត្រូវគិតដកចេញពីបរិមាណរូបិយវត្ថុនៅក្នុងចរាចរដែលចុះ ក្នុងបញ្ជីធនាគារកណ្ដាលហើយត្រូវ ចាត់ទុកជាប្រាក់ចំណូលរបស់ធនាគាកណ្ដាល ។

មាត្រា ៤៧: បើមានជនណាស្នើសុំប្តូរក្រដាសប្រាក់ឬកាក់ដែលធនាគារកណ្ដាល បោះផ្សាយនោះធនាគារកណ្ដាលត្រូវតែប្តូរអោយតាមតម្លៃស្មើដោយគ្មានគិតសោហ៊ុយអ្វីទាំងអស់ ។

មាត្រា ៤៨: ហាមមិនអោយផលិតជាថ្មីឡើងវិញនូវក្រដាស ប្រាក់កាក់ មូលប្បទានប័ត្រ មូលប័ត្រ ឬប័ណ្ណទូទាត់ផ្សេងៗទោះជារៀល ជាកាក់ ជាសេនក្តីឬជារូបិយវត្ថុបរទេសក្តីនិងមិនអោយបង្កើតវត្ថុទាំងឡាយណា ដែលត្រាប់តាមក្រដាសប្រាក់កាក់ មូលប្បទានប័ត្រ ឬប័ណ្ណទូទាត់ផ្សេងៗដោយពុំបានទទួលការអនុញ្ញាតជា លាយលក្ខណ៍អក្សរពីធនាគារកណ្ដាលជាមុននោះទេ ។

មាត្រា ៤៩: ធនាគារកណ្ដាលត្រូវតែគ្រប់គ្រងដោយផ្ទាល់នូវសន្និធិរូបិយវត្ថុបំរុងធ្វើផែនការបោះផ្សាយនិង ធានាការផ្តល់ជាទៀងទាត់នូវក្រដាសប្រាក់និងកាក់ ដើម្បីបំពេញតម្រូវការរូបិយវត្ថុក្នុងព្រះរាជាណាចក្រ កម្ពុជាទាំងបរិមាណនិងគុណភាព ។

មាត្រា ៥០: ធនាគារកណ្តាលត្រូវដកចេញពីចរាចរនូវរូបិយវត្ថុ មិនគ្រប់លក្ខណៈប្រើប្រាស់ដើម្បីបំផ្លាញចោលហើយប្តូរថ្មីជំនួសវិញ ។

មាត្រា ៥១: ធនាគារកណ្តាលអាចបដិសេធមិនប្តូរក្រដាសប្រាក់និង កាសបើសិនជារូបភាពវាលែងមានភាពច្បាស់លាស់បាត់បង់រូបភាពដើម ឬ ធ្លុះធ្លាយឬដែលបាត់បង់ទំហំ ៣០% (សាមសិបភាគរយ)ឬលើសពីនេះ ។ រូបិយវត្ថុទាំងនេះត្រូវដកចេញពីចរាចរហើយបំផ្លាញចោលដោយគ្មានសំណងចំពោះម្ចាស់ទេ លើកលែងតែករណីពិសេសដែលធនាគារកណ្តាល អាចយល់ព្រមសងមួយចំណែកឬទាំងអស់ ។

មាត្រា ៥២: ក្រដាសប្រាក់ក្លែងក្លាយដែលយកមកបង់ ឬ ប្តូរត្រូវរឹបអូសដោយគ្មានសំណងហើយត្រូវជូនពតិមានទៅអាជ្ញាធរមានសមត្ថកិច្ច ។

មាត្រា ៥៣: ម្ចាស់ប្រាក់មិនអាចទាមទារពីធនាគារកណ្តាលអោយសង ចំពោះក្រដាសប្រាក់ ឬកាសណាដែលខ្លួនធ្វើអោយបាត់បង់ឬធ្វើអោយអន្តរាយឡើយ ។ ធនាគារកណ្តាលអាចដកហូតយកដោយគ្មានថ្លៃនូវក្រដាស ប្រាក់ដែលមានការខូចខាតរូបភាពក្រៅជាពិសេសចំពោះក្រដាសប្រាក់ណាដែលមានសរសេរ លាបពណ៌ បោះពុម្ព បោះត្រាឬបិទវត្ថុស្អិតពីលើឬធ្លុះធ្លាយឬបាត់រូបភាពដោយប្រការណាក៏ដោយ ។

មាត្រា ៥៤: បរិមាណក្រដាសប្រាក់និងកាសកំពុងធ្វើចរាចរ ត្រូវកត់ត្រាចូលក្នុងគណនីទ្រព្យអកម្មរបស់ធនាគារកណ្តាលដោយមិនគិតបញ្ចូលនូវបរិមាណក្រដាសប្រាក់និងកាសនៅក្នុងសន្និធិរូបិយវត្ថុបំរុងទេ ។

ជំពូកទី ១០

គណនីនិងការពិនិត្យគណនី

មាត្រា ៥៥: ការិយបរិច្ឆេទគណនេយ្យនៃធនាគារកណ្តាល ចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករាដល់ថ្ងៃទី ៣១ ខែ ធ្នូ ជារៀលរាល់ឆ្នាំ ។

មាត្រា ៥៦: ធនាគារកណ្តាលត្រូវ :

១-កាន់កាប់បញ្ជីគណនេយ្យ និង បញ្ជីផ្សេងៗទៀតហើយត្រូវកត់ត្រាគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុដែល ឆ្លុះបញ្ចាំងដោយប្រាកដប្រជានូវស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួនស្រប

ទៅតាម គោលការណ៍និងបែបបទគណនេយ្យ ដែលត្រូវបានទទួលស្គាល់ជាទូទៅសំរាប់ធនាគារកណ្តាល ។

២–រៀបចំនិងចេញផ្សាយរបាយការណ៍សង្ខេបប្រចាំខែស្តីពីស្ថានភាពនៃសកម្មភាពរបស់ខ្លួន ។

៣–ដាក់ជូនរាជរដ្ឋាភិបាលនិងរដ្ឋសភាក្នុងអំឡុង ៦ខែ បន្ទាប់ពីការបញ្ចប់ការិយបរិច្ឆេទនីមួយៗនូវច្បាប់ចម្លងនៃគណនីប្រចាំឆ្នាំ ព្រមទាំងរបាយការណ៍ដែលអាចចេញផ្សាយបាន ស្តីពីប្រតិបត្តិការរបស់ខ្លួននិងស្តីពីស្ថានភាពសេដ្ឋកិច្ចរូបិយវត្ថុក្នុងការិយបរិច្ឆេទកន្លងមក ។

មាត្រា ៥៧: ការពិនិត្យបញ្ជីហិរញ្ញវត្ថុរបស់ធនាគារកណ្តាលត្រូវធ្វើឡើងដោយគណៈកម្មការពិសេសមួយដែលតែងតាំងដោយរាជរដ្ឋាភិបាល ។

ជំពូកទី ១១

បទបញ្ញត្តិផ្សេងៗ

មាត្រា ៥៨: ធនធាន ទ្រព្យសម្បត្តិ ប្រតិលាភ ប្រតិបត្តិការនិងអាជីវកម្មរបស់ធនាគារកណ្តាលត្រូវបានលើក លែងមិនយកពន្ធនិងអាករឡើយ ។

មាត្រា ៥៩: ធនាគារកណ្តាលមិនត្រូវចូលហ៊ុនក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬក្នុងសហគ្រាសដែលមានលក្ខណៈអោយឧស្សាហកម្មឬពាណិជ្ជកម្មឡើយ លើកលែងតែគ្រឹះស្ថានដែលមានសកម្មភាពផ្សារភ្ជាប់ជាមួយសកម្មភាពរបស់ធនាគារកណ្តាល ដូចជាការវាយតម្លៃនិងការពិនិត្យកិច្ចសន្យាធានា ប្រព្រឹត្តកម្មនិងការ បញ្ជូនទិន្នន័យ ការបោះពុម្ពឯកសារហិរញ្ញវត្ថុ ការផាត់ទាត់សងគ្នា ការបញ្ជូនសារលិខិតឬការជម្រះបញ្ជីទ្រព្យសម្បត្តិក្នុងល័ក្ខខ័ណ្ឌដែលទឹកប្រាក់ចូលហ៊ុនទាំងអស់នោះមិនលើសពី ៥%(ប្រាំភាគរយ) នៃមូលនីធិរបស់ ខ្លួនផ្ទាល់ ។

មាត្រា ៦០ : ធនាគារកណ្តាលមិនត្រូវធ្វើលទ្ធកម្មដោយទិញឬដោយភតិសន្យានូវសិទ្ធិ ពិតប្រាកដលើ អចលន ទ្រព្យ លើកលែងតែទ្រព្យសម្បត្តិណាដែលចាំបាច់សំរាប់ធ្វើសកម្មភាពនិងមុខងាររបស់ខ្លួនឬសំរាប់ការងារ សង្គមកិច្ចចំពោះបុគ្គលិករបស់ខ្លួន ។

បទបញ្ញត្តិនៃមាត្រានេះពុំឃាត់ធនាគារកណ្ដាលមិនអោយធ្វើលទ្ធកម្មក្នុងក្របខ័ណ្ឌ នៃការទូទាត់សងឥណទេយ្យរបស់ខ្លួននូវសិទ្ធិដែលមានចែងក្នុងមាត្រា ៥៩ ឬ មាត្រានេះទេ ។

មាត្រា ៦១: រាល់ប្រកាស បទបញ្ជា សារាចរនិងបណ្ដាសេចក្ដីណែនាំផ្សេងៗដែលចេញដោយធនាគារកណ្ដាលសំរាប់អនុវត្តជាទូទៅចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធ្វើការផ្សព្វផ្សាយក្នុងរាជកិច្ចហើយ ចូលជាធរមានបញ្ញត្តិចាប់តាំងពីថ្ងៃចេញផ្សាយនោះឬតាមកាលកំណត់ដែលមានចែងក្នុង ប្រកាស បទបញ្ជា សារាចរនិងសេចក្ដីណែនាំផ្សេងៗទាំងនោះ ។

មាត្រា ៦២: ដើម្បីអនុវត្តខ្លឹមសារនៃច្បាប់នេះ ធនាគារកណ្ដាលអាចធ្វើបណ្ដឹងខាងផ្នែករដ្ឋប្បវេណីភ្ជាប់ជាមួយផ្នែកព្រហ្មទណ្ឌនូវគ្រប់ដំណាក់កាលនៃនីតិវិធី ។

មាត្រា ៦៣: ការកម្រិតឥណទាននៅក្នុងចំណុច ៣ មាត្រា ២៥ នៃច្បាប់នេះ ត្រូវអនុវត្តចំពោះឥណទានណា ដែលត្រូវផ្ដល់អោយក្រោយថ្ងៃដែលច្បាប់នេះចូលជាធរមាន ។

ជំពូកទី ១២

ទោសប្បញ្ញត្តិ

មាត្រា ៦៤ : ជនណាពុំព្រមទូទាត់រូបិយវត្ថុដែលមានតម្លៃនីត្យានុកូលនិងមានតេជានុភាពធ្វើសេរីកាលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជននោះនឹងត្រូវបានផ្ដន្ទាទោស ពិន័យជាប្រាក់ស្មើនឹង ១០០ដងនៃទឹកប្រាក់ ដែលពុំព្រមទូទាត់នោះ ។

មាត្រា ៦៥: អ្នកក្លែងក្រដាសប្រាក់ឬកាសដែលជារូបិយវត្ថុមានតម្លៃនីត្យាកូលនៅលើដែន ដីនៃព្រះរាជាណាចក្រកម្ពុជាឬនៅលើដែនដីនៃរដ្ឋដទៃទៀតនឹងត្រូវបានផ្ដន្ទាទោស ដាក់ពន្ធនាគារពី២០ឆ្នាំដល់អស់មួយជីវិត ។ វត្ថុតាងដែលរឹបអូសបានត្រូវទុកជាសម្បត្តិរដ្ឋឬបំផ្លាញចោល ។

មាត្រា ៦៦: ជនណាប្រព្រឹត្តិដោយចេតនាដោយបញ្ចូលក្នុងចរាចរ ឬ រក្សាទុកសំរាប់ចរាចរនូវក្រដាសប្រាក់ ឬ កាសក្លែងក្លាយ ជននោះនឹងត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ។

មាត្រា ៦៧: ជនណាប្រើប្រាស់ឬរក្សាទុកដោយគ្មានការអនុញ្ញាត ពីធនាគារកណ្តាលនូវ បណ្តាសម្ភារៈឧបករណ៍គ្រឿងយន្តនិងប្រដាប់សំរាប់ផលិតក្រដាសប្រាក់ឬកាស ជននោះនឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ។ ឯវត្ថុតាងនិងត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋឬបំផ្លាញចោល ។

មាត្រា ៦៨: ជនណាទទួលក្រដាសប្រាក់ ឬ កាសដែលក្រោយមកបានដឹងថាជាក្រដាសប្រាក់ ឬ កាសក្លែងក្លាយហើយនៅតែយកទៅដាក់អោយធ្វើចរាចរវិញ ជននោះត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹង ១០០ដងនៃ ទឹកប្រាក់នោះ ។

មាត្រា ៦៩: ដើម្បីអនុវត្តនិងបំពេញមុខងារអោយបានល្អតាមច្បាប់នេះ ធនាគារកណ្តាលអាចស្នើសុំពត៌មាន ដែលខ្លួនត្រូវការពីរូបវន្តបុគ្គលឬនីតិបុគ្គលិកដែលពាក់ព័ន្ធ រួមទាំងពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិង អង្គភាពក្រោមឱវាទទៀតផង ។

ជនណា ដែលមិនព្រមផ្តល់ពត៌មានដែលធនាគារកណ្តាលបានស្នើសុំស្របតាមមាត្រានេះឬ ដែលមានចេតនាផ្តល់ពត៌មានខុសឬបំភ្លៃ ជននោះនឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០៛ (មួយលានរៀល)ដល់ ១០.០០០.០០០៛ (ដប់លានរៀល) និង /ឬដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ ឆ្នាំ ។

មាត្រា.៧០: ជនណាគ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬធ្វើសកម្មភាពមានលក្ខណៈជាធនាគារដូចជា ឥណទាន ជំនួយជើងសារូបិយប័ណ្ណ កាប្តូររូបិយប័ណ្ណ ការទទួលប្រាក់ពីសាធារណជន ការគ្រប់គ្រងមធ្យោបាយទូទាត់ ប្រតិបត្តិការលើមូលប័ត្រ អាជីវកម្មមាសលោហធាតុនិងត្បូងថ្មមានតម្លៃដោយគ្មានការអនុញ្ញាត ពីធនាគារកណ្តាលត្រូវបញ្ឈប់សកម្មភាពភ្លាមតាមអធិបញ្ញារបស់ធនាគារកណ្តាល ។ ជនដែលប្រព្រឹត្តិល្មើសនឹងអធិបញ្ញានេះនឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០៛ (មួយលានរៀល)ដល់ ១០.០០០.០០០ ៛ (ដប់លានរៀល)និង/ឬដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

មាត្រា ៧១: ជនណាប្រព្រឹត្តិល្មើសនឹងមាត្រា ១៥ ចំណុច ១ នឹងមាត្រា ១៦ និងត្រូវបានផ្តន្ទាទោសពិន័យ ជាប្រាក់ពី ១.០០០.០០០ ៛ (មួយលានរៀល) ដល់ ១០.០០០.០០០ ៛ (ដប់លានរៀល) និង/ឬដាក់ពន្ធ នាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

ជំពូកទី ១៣

អវសានប្បញ្ញត្តិ

មាត្រា ៧២: បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខា ព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
នរោត្តម រណឫទ្ធិ ហ៊ុន សែន

បានបង្គំទូលថ្វាយ និងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២
អគ្គទេសាភិបាលធនាគារជាតិ នៃ
កម្ពុជា

ថៅ ម៉េងឃាត

* * *

ព្រះរាជក្រម នស/រកម/០១៩៦/២៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រកាសអោយប្រើ

ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ដែលរដ្ឋសភាបានអនុម័ត នាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីដូចតទៅ :

ច្បាប់

ស្តីពី

ការបង្ក្រាបល្បែងស៊ីសង

ជំពូកទី ១

បទបញ្ញត្តិទូទៅ

មាត្រា ១: ត្រូវហាមឃាត់ជាដាច់ខាតការលេងល្បែងស៊ីសងគ្រប់ប្រភេទ នៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

មាត្រា ២: រាល់លិខិតដែលបានអនុញ្ញាតអោយបើកល្បែងស៊ីសងក្រៅពីការអនុញ្ញាតរបស់ រាជ-រដ្ឋាភិបាល ត្រូវទុកជាមោឃៈ ។

ជំពូកទី ២

ស្ថាប័នមានសមត្ថកិច្ច

មាត្រា ៣: ការបង្ក្រាបនិងការទប់ស្កាត់ ការលេងល្បែងស៊ីសងគ្រប់ប្រភេទ ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។

ជំពូកទី ៣

ទោសប្បញ្ញត្តិ

មាត្រា ៤: ជនណាលេងល្បែងស៊ីសងជននោះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយម៉ឺនរៀល (១០.០០០៛០០) ដល់ប្រាំម៉ឺនរៀល (៥០.០០០៛០០) ឬដាក់គុកពីមួយសប្តាហ៍ដល់មួយខែ ។

ក្នុងករណីពុំរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំម៉ឺនរៀល (៥០.០០០៛) ដល់ប្រាំសែនរៀល (៥០០.០០០៛) និងដាក់គុកពីមួយខែដល់មួយឆ្នាំ ។

មាត្រា ៥: ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលានរៀល (៥.០០០.០០០៛០០) ដល់ម្ភៃលានរៀល (២០.០០០.០០០៛០០)និង ដាក់គុកពីមួយឆ្នាំដល់ប្រាំឆ្នាំ ចំពោះអ្នកបើកកន្លែងលេងល្បែងស៊ីសង អ្នកកាន់កាប់ល្បែងស៊ីសង អ្នកចាត់ចែងនិងភ្នាក់ងារស៊ីសង ។

ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់និងដាក់គុកខាងលើនេះជាអតិបរមា ។

មាត្រា ៦: កាលណានៅក្នុងវង់ល្បែងមានអនីតិជនម្នាក់ឬច្រើននាក់នៅជាមួយផង ទោសដែលបានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃច្បាប់នេះ ត្រូវយកមកអនុវត្តដល់អតិបរមា ។

មាត្រា ៧: ក្នុងករណីណាក៏ដោយ ប្រាក់ដែលដាក់ក្នុងវង់ល្បែង ប្រាក់ដែលមាននៅនឹងខ្លួនអ្នកចាត់ចែងល្បែងនៅនឹងខ្លួនមេល្បែង នៅនឹងខ្លួនភ្នាក់ងារល្បែង នៅនឹងខ្លួនអ្នកជួយស៊ីសងក្នុងវង់ល្បែង នៅនឹងខ្លួនអ្នកទទួលភារកិច្ចខាងគណនេយ្យ នៅនឹងខ្លួនអន្តរការីនិងនៅនឹងខ្លួនអ្នកលេងល្បែង ត្រូវភ្នាក់ងារមានសមត្ថកិច្ចចាប់រឹបអូសហើយធ្វើកំណត់ហេតុអោយបានត្រឹមត្រូវបញ្ជូនទៅតុលាការ ។

វត្ថុតាងសំរាប់បម្រើអោយការលេងល្បែងនោះ ក៏ត្រូវរឹបអូសដូចខាងលើនេះដែរ ។

មាត្រា ៨: ការផលិត ការនាំចូលដើម្បីធ្វើអាជីវកម្ម ការលក់ ឧបករណ៍ល្បែងស៊ីសងគ្រប់ប្រភេទដោយគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំសែនរៀល (៥០០.០០០៛០០) ដល់ប្រាំលានរៀល(៥.០០០.០០០៛០០) និងដាក់គុកពីមួយខែដល់មួយឆ្នាំ ។

ឧបករណ៍ជាវត្ថុតាងខាងលើនេះត្រូវរឹបអូស ។ ក្នុងករណីពុំរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់និងដាក់គុកខាងលើនេះជាអតិបរមា ។

មាត្រា ៩: ប្រាក់និងវត្ថុតាងដែលរឹបអូសបានដូចមានចែងក្នុងមាត្រា ៧ និងមាត្រា ៨ នៃច្បាប់នេះ ត្រូវ បញ្ជូនទៅតុលាការដើម្បីសំរេចរឹបអូសជាសម្បត្តិរដ្ឋឬបំផ្លាញចោល ។

ចំពោះប្រាក់រង្វាន់សំរាប់ភ្នាក់ងារមានសមត្ថកិច្ច អង្គភាពនិងជនដែលបានចូលរួមក្នុងកិច្ចប្រតិបត្តិការត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១០: ក្រៅពីរាជរដ្ឋាភិបាល អាជ្ញាធរណាក៏ដោយក៏គ្មានសិទ្ធិចេញលិខិតអនុញ្ញាតអោយបើកល្បែងស៊ីសងនៅទីណាក៏ដោយជាដាច់ខាត ។ មន្ត្រីឬភ្នាក់ងាររាជការណាដែលនៅតែចេញលិខិតអនុញ្ញាតលេងបើកអោយល្បែងស៊ីសង ត្រូវផ្តន្ទាទោសដាក់គុកពីមួយឆ្នាំដល់ប្រាំឆ្នាំ ។

មាត្រា ១១: ជនណាដែលចេញមុខការពារវង់ល្បែងស៊ីសងឬបនល្បែងស៊ីសងគ្រប់ប្រភេទនៅទីណាក៏ដោយ ត្រូវផ្តន្ទាទោសដាក់គុកពីមួយឆ្នាំដល់ប្រាំឆ្នាំ ។

ជំពូកទី ៤

អវសានប្បញ្ញត្តិ

មាត្រា ១២: បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៣: ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយ និងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២
សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ស ខេង យូ ហុកគ្រី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខា ព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

ព្រះរាជក្រម នស/រកម/០១៩៦/២៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរនិងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រកាសអោយប្រើ

ច្បាប់ស្តីពីការផ្តល់សច្ចាប័ន លើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៤ ដែលរដ្ឋសភាបានអនុម័ត នាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមាន សេចក្តីដូចតទៅ ÷

ច្បាប់

ស្តីពី

ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ចនិងបច្ចេកទេស ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៤ រវាង ព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិន

* * *

មាត្រា ១: ផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិង បច្ចេកទេស ដែលរាជរដ្ឋាភិបាលកម្ពុជាខ្ចីពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន នូវទឹកប្រាក់ចំនួនប្រាំបីលានប្រាំមួយសែនដុល្លារ អាមេរិក (៨.៦០០.០០០ USD) ដើម្បីជួសជុលសមិទ្ធផលនានាដែលបានកសាងឡើងដោយជំនួយចិននិងទូទាត់ការនាំចូលទំនិញមួយចំនួន ។

មាត្រា ២: ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយ និងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការ
នីតិសម្បទា និងអភិវឌ្ឍន៍ និងជា
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខា ព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១៥៣០ រៀល